សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សិទ្ធិ និងករណីយកិច្ចក្រោយពេលលែងលះក្នុងចំណងអាពាហ៍ពិពាហ៍

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ផន សុខគីម**
កញ្ញា **ហ៊ាង រក្សា**

ណែនាំដោយ
អ្នកគ្រូ **សំណាង ផលដេត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ផន សុខគីម** និង **ហ៊ាង រក្សា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០២០-២០២៤។

**សូមគោរពប្រណិប័តន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖**

**លោកឪពុក អ្នកម្តាយ និងអាណាព្យាបាល** ដែលបានផ្តល់កំណើតខិតខំចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅដល់កូនឱ្យបានស្គាល់នូវអ្វីដែលជាផ្លូវល្អ ផ្លូវអាក្រក់សម្រាប់អនាគតរបស់កូន។ ចំពោះមហាគុណរបស់លោកទាំងពីរ កូនពុំអាចនឹងរកអ្វីយកមកប្រៀបស្មើទៅនឹងគុណរបស់លោកទាំងពីរនោះទេ ហើយកូនក៏មិនអាចបំភ្លេចបាននូវព្រះគុណដ៏បវរនេះបានឡើយ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា និងលោក លោកស្រី សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ** ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យនៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** និងលោកគ្រូ អ្នកគ្រូ ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន និងណែនាំចំណេះដឹងល្អៗផ្សាភ្ជាប់នឹងសង្គមកម្ពុជាបច្ចុប្បន្ន។

ជាពិសេសសាស្ត្រាចារ្យបណ្ឌិត**សំណាង ផលដេត** ដែលជាសាស្ត្រាចារ្យប្រកបទៅដោយគតិបណ្ឌិត ដែលបានផ្តល់កិត្តិយសណែនាំ ជួយជ្រោមជ្រែង ផ្តល់នូវគំនិតយោបល់ ជួយកែតម្រូវរាល់កំហុសឆ្គងក្នុងការសរសេរសារណានេះ តាំងពីដំណាក់កាលដំបូងរហូតដល់ទទួលបានជោគជ័យ លោកសាស្ត្រាចារ្យបានផ្តល់ឱ្យនូវគ្រឹះយ៉ាងសំខាន់ក្នុងការចងក្រងសារណាមួយនេះឡើង។

អ្នកនិពន្ធ ម្ចាស់ឯកសារ អ្នកសិក្សាស្រាវជ្រាវ និងម្ចាស់ស្នាដៃទាំងអស់ដែលបានចូលរួមជាជាលិកាដ៏សំខាន់ដល់យើងខ្ញុំជាទុនសម្រាប់ធ្វើការសិក្សា និងបំពេញភាពខ្វះចន្លោះនៃកិច្ចការស្រាវជ្រាវនេះ។

ជាចុងក្រោយយើងខ្ញុំទាំងពីរ  សូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ **លោកឪពុក អ្នកម្តាយ ឯកឧត្តមបណ្ឌិត លុយ ចណ្ណា និងលោក លោកស្រី សាកលវិទ្យាធិការរង** ព្រមទាំង លោក លោកស្រី សាស្ត្រាចារ្យនៃ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច** និងលោកគ្រូ អ្នកគ្រូទាំងអស់ សូមមានសុខភាពល្អ សុវត្ថិភាពគ្រប់ទីកន្លែង និងទទួលបានសម្រេចរាល់កាងារភារកិច្ចទាំងពួង និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីទទួលបានការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ៤ (បួន) ឆ្នាំកន្លងមក និងបានសិក្សាលើមុខវិជ្ជាជាច្រើនទាំងផ្នែកនីតិឯកជន និងផ្នែកសាធារណៈរួចមក យើងខ្ញុំទាំងពីរបានទទួលនូវចំណេះដឹងជាច្រើនទៅលើមុខវិជ្ជាទាំងអស់នោះ ក្រោមការខិតខំប្រឹងប្រែងយកចិត្តទុកដាក់បង្ហាត់បង្រៀនពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្ត្រចារ្យទាំងអស់។ កត្តានេះហើយ ទើបធ្វើឱ្យយើងខ្ញុំទាំងពីរ អាចឈានដល់ការចងក្រងឯកសារសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។ ការសរសេរសារណាបញ្ចប់ការសិក្សានេះផងដែរយើងខ្ញុំទាំងពីរបានសម្រេចជ្រើសរើសប្រធានបទមួយដែលទាក់ទងនឹងផ្នែកនីតិឯកជនដែលមានចំណងជើងថា៖ **សិទ្ធិ និងករណីយកិច្ចក្រោយពេលលែងលះក្នុងចំណងអាពាហ៍ពិពាហ៍**។ ការជ្រើសរើសប្រធាននេះឡើងមក គឺដើម្បីឱ្យបុគ្គលគ្រប់រូបបានអាន និងយល់ដឹងកាន់តែច្បាស់អំពីសិទ្ធិ និងករណីយកិច្ចដែលកើតមានចំពោះបុគ្គលក្រោយការលែងលះ តើពួកគាត់មានសិទ្ធិ និងករណីយកិច្ចដែលត្រូវកំណត់ដោយច្បាប់បែបណា អ្នកណាដែលអាចទទួលបានអំណាចមេបា ហើយថាតើអ្នកដែលមានអំណាចមេបា និងអ្នកដែលគ្មានអំណាចមេបាត្រូវមានសិទ្ធិ និងករណីយកិច្ចអ្វីខ្លះចំពោះកូនបន្ទាប់ពីមានការលែងលះ។

យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សារណាមួយនេះនឹងអាចជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់សិស្សនិស្សិត ក៏ដូចជាប្រជាពលរដ្ឋគ្រប់រូបដែលមានបំណងចង់ស្វែងយល់បន្ថែមទាក់ទងពី សិទ្ធិ និងករណីយកិច្ចដែលមានក្រោយការលែងលះដែលមានកំណត់ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ ហើយឯកសារសារណាមួយនេះនឹងត្រូវបានរក្សាទុកជាស្នាដៃដល់អ្នកសិក្សាជំនាន់ក្រោយ ដើម្បីមានភាពងាយស្រួលក្នុងសិក្សាស្រាវជ្រាវ និងស្វែងយល់បន្ថែមពីបញ្ហាទាំងឡាយដែលទាក់ទងនឹងប្រធានបទមួយនេះ។

ជាចុងក្រោយ យើងខ្ញុំក៏សូមអភ័យទោសទុកជាមុនផងដែរ ប្រសិនបើមានចំណុចខ្វះខាតណាមួយ ទៅលើពាក្យពេចន៍ ខ្លឹមសារ អត្ថន័យ ឬអក្ខរាវិរុទ្ធទាំងឡាយដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះដោយអចេតនា ហើយយើងខ្ញុំនឹងទទួលនូវការរិះគន់លើអត្ថបទនេះពីសំណាក់អ្នកអាន ដើម្បីជាការស្ថាបនាឱ្យកាន់តែប្រសើរឡើង។

# មាតិកា

## សេចក្តីផ្តើម


១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទនៃការស្រាវជ្រាវ ........ ១

៣.គោលបំណងនៃការស្រាវជ្រាវ ........ ១

៤.ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ២

៦.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ២

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២


## ជំពូកទី១

## សញ្ញាណទូទៅនៃការលែងលះ


១.១.និយមន័យនៃការលែងលះ ........ ៣

១.២.ប្រភេទនៃការលែងលះ ........ ៣

១.២.១.ការលែងលះដោយការព្រមព្រៀង ........ ៣

១.២.២.ការលែងលះដោយពុំតាមការព្រមព្រៀង ........ ៤

១.២.២.១.ការបានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ ........ ៤

១.២.២.២.ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ ........ ៥

១.២.២.៣.ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ ........ ៥

១.២.២.៤.សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ ........ ៥

១.២.២.៥. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ........ ៥


## ជំពូកទី២

## ការកំណត់អំណាចមេបាចំពោះកូន


២.១ អ្នកមានអំណាចមេបា ........ ៧

២.១.១.អ្នកមានអំណាចមេបា ........ ៧

២.១.១.១.អំណាចមេបារួម ........ ៧

២.១.១.២. អំណាចមេបាទោល ........ ៧

២.១.២.ការកំណត់អ្នកមានអំណាចមេបាក្រោយលែងលះ ........ ៨

២.១.២.១.អំណាចមេបាកំណត់ការព្រមព្រៀង ................................................................ ៨
២.១.២.២. ការកំណត់អំណាចមេបាក្នុងករណីលែងលះតាមឆន្ទានុសិទ្ធិរបស់តុលាការ ........................ ៩
២.២. ករណីយកិច្ចអ្នកមានអំណាចមេបា និងអ្នកពុំមានអំណាចមេបា ........................................ ១០
២.២.១.សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា ........................................................ ១០
២.២.១.១. សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន ........................................................................ ១០
២.២.១.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង ....................................................................១២
២.២.១.៣.ការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាចំពោះអំពើអនីត្យានុកូល ........................ ១៤
២.២.២.សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងអ្នកគ្មានអំណាចមេបា ................................................ ១៥
២.២.២.១.ការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ................................................................ ១៥
២.២.២.២.ការទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន ..........................................................១៧
២.២.២.៣.ការពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន ............................................................ ១៨
២.៣. ការផ្លាស់ប្តូរអំណាចមេបា .......................................................................................................២០
២.៣.១. ការព្យួរ ឬការដកហូតអំណាចមេបា .......................................................................................២០
២.៣.២. ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ........................................................................២១
២.៤. ការបញ្ចប់អំណាចមេបា .............................................................................................................២២

## ជំពូកទី៣

## ការបែងចែកទ្រព្យសម្បត្តិនិងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

៣.១. ការបែងចែកទ្រព្យសម្បត្តិ .......................................................................................................២៤
៣.១.១.ការបែងចែកទ្រព្យសម្បត្តិតាមកិច្ចសន្យា ...................................................................................២៤
៣.១.២.ការបែងចែកទ្រព្យសម្បត្តិតាមច្បាប់ .........................................................................................២៥
៣.២.ការបែងចែកកាតព្វកិច្ចបំណុលក្រោយការលែងលះ .......................................................................២៦
៣.៣.សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន ........................................................................................ ២៧
**សេចក្តីសន្និដ្ឋាន**.......................................................................................................................២៩
**អនុសាសន៍**............................................................................................................................... ៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សក្នុងសង្គមការប្រាស្រ័យទាក់ទងគ្នាជាកត្តាចាំបាច់ដែល ជៀសមិនផុតអំពីទំនាក់ទំនងនេះឡើយ។ ម៉្យាងវិញទៀតនៅក្នុងការប្រាស្រ័យទាក់ទងគ្នានេះផងដែរមនុស្សរមែង តែងតែប្រព្រឹត្តនូវកំហុសដែលជាមូលហេតុចម្បងធ្វើឱ្យមានជម្លោះកើតឡើង។ បើយើងសង្កេតមើលទៅលើការ ដោះស្រាយជម្លោះ ឬវិវាទរបស់មនុស្សវិញក្រៅពីការចរចារ សម្រុះសម្រួលគ្នា បទដ្ឋានគតិយុត្ត និងបទបញ្ញត្តិ ផ្សេងៗទៀតត្រូវបានបង្កើតឡើងជាបន្តបន្ទាប់ វាអាស្រ័យទៅលើតម្រូវការ និងបរិបទនៃសង្គមដើម្បីស្វែងរកនូវ ដំណោះស្រាយដ៏សមស្រប និងប្រកបទៅដោយប្រសិទ្ធភាព។

ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍ តាមផ្លូវតុលាការដោយតម្រូវឱ្យមានសេចក្តីសម្រេចពី តុលាការ ដើម្បីបញ្ជាក់អំពីការរំលត់ចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ វាគឺជាបញ្ហាមួយដែលគ្រួសារជាច្រើន នៅព្រះរាជាណាចក្រកម្ពុជាបានកំពុងជួបប្រទះ។ ការកសាងគ្រួសារដែលបង្កើតឡើងដោយអាពាហ៍ពិពាហ៍ កើតមានជាហូរហែរ ហើយការលែងលះដោយសារការរស់នៅមិនចុះសម្រុងគ្នា និងដោយមូលហេតុផ្សេងៗក៏មាន ជាបន្តបន្ទាប់ដែរ។ ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីមិនមានអានុភាពតាមផ្លូវច្បាប់ ពោលគឺប្តីប្រពន្ធត្រូវចុះ សំបុត្រអាពាហ៍ពិពាហ៍ ទើបពួកគេក្លាយជាប្តីប្រពន្ធស្របច្បាប់។ ហេតុនេះហើយ នៅពេលចំណង អាពាហ៍ពិពាហ៍ត្រូវបានរំលាយសិទ្ធិ និងករណីយកិច្ចមួយចំនួនត្រូវបានកើតមានឡើងដូចជាករណីយកិច្ចក្នុងការ មើលថែ គ្រប់គ្រង ចិញ្ចឹមបីបាច់ អប់រំ សោហ៊ុយចាំបាច់សម្រាប់អប់រំកូន ព្រមទាំងការបែងចែកទ្រព្យសម្បត្តិជា អាទិ៍ ដែលត្រូវបានកំណត់អំពី សិទ្ធិនិងករណីយកិច្ចក្រោយការលែងលះ។ ហើយសិទ្ធិនិងករណីយកិច្ចទាំង នោះមានចែងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

## ២.ចំណោទនៃការស្រាវជ្រាវ

១.តើត្រូវកំណត់អ្នកមានអំណាចមេបាបែបណាក្រោយការលែងលះ?

២.តើអ្នកមានអំណាចមេបាមានករណីយកិច្ចបែបណាខ្លះ?

៣. តើអ្នកគ្មានអំណាចមេបាមានករណីយកិច្ចបែបណាខ្លះ?

៤.តើក្រោយការលែងលះទ្រព្យសម្បត្តិត្រូវបែងចែកដោយរបៀបណា?

៥.តើសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូនអាចបង់សរុបបានឬទេ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះ គឺដើម្បីចូលរួមចំណែកបង្កើននូវចំណេះដឹង និងព្រមទាំង ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីសិទ្ធិនិងករណីយកិច្ចដែលសហព័ទ្ធត្រូវអនុវត្តក្រោយការលែងលះ។

មួយវិញទៀតការស្រាវជ្រាវប្រធានបទមួយនេះ ធ្វើឱ្យខ្ញុំទាំងពីរយល់ដឹងអំពីមូលហេតុ និងការកំណត់សិទ្ធិនិងករណីយកិច្ចដែលអ្នកមានអំណាចមេបា និងអ្នកដែលមិនទទួលបានអំណាចមេបាមានចំពោះកូន និងសិទ្ធិអំណាចដែលមានទៅលើទ្រព្យសម្បត្តិក្រោយការលែងលះ។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនេះ បង្ហាញអំពីសិទ្ធិអំណាចមេបាក្រោយការលែងលះ អំពីការបែងចែងទ្រព្យសម្បត្តិនិងសោហ៊ុយចាំបាច់ដើម្បីអប់រំកូន នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលស្ថិតនៅក្នុងគន្ថីទី៧ស្តីពីញាតិ ជំពូកទី៣ អាពាហ៍ពិពាហ៍ ផ្នែកទី៤ ការលែងលះគ្នា កថាខណ្ឌទី១ មូលហេតុនៃការលែងលះគ្នា ជំពូកទី៥ អំណាចមេបា ផ្នែកទី១ បទប្បញ្ញត្តិទូទៅ ផ្នែកទី២ ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នានិងការទទួលខុសត្រូវ ផ្នែកទី៣ សិទ្ធិនិងករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា ផ្នែកទី៤ ការព្យួរនិងការដកហូតអំណាចមេបា ផ្នែកទី៥ សិទ្ធិអំណាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ផ្នែកទី៦ ការព្យួរ និងការដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិ និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវអត្ថបទមួយនេះ បានផ្តល់នូវសារៈសំខាន់ជាច្រើនដល់ប្រជាជនទូទៅ និងអ្នកសិក្សាទាំងអស់ដែលបានអានឱ្យបានយល់ច្បាស់ និងកាន់តែស៊ីជម្រៅទាក់ទងទៅនឹងសិទ្ធិ និងករណីយកិច្ចដែលភាគីមាននៅក្រោយការលែងលះក្នុងចំណងអាពាហ៍ពិពាហ៍។ ម៉្យាងទៀតក៏អាចទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវ និងនិស្សិតទាំងអស់ដែលមានគោលបំណងសិក្សាទៅលើប្រធានបទនេះដែរ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រភពទិន្នន័យ ដែលត្រូវបានក្លាយជាមូលដ្ឋានក្នុងការសរសេរប្រធានបទសារណានេះ មានជាអាទិ៍ដូចជា ច្បាប់ និងបទដ្ឋានគតិយុត្តនានា ដែលកំពុងតែត្រូវបានអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន ក៏ដូចជាឯកសារជំនួយស្មារតីផ្នែកច្បាប់ដែលត្រូវបានចងក្រងដោយអ្នកជំនាញការផ្នែកច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសជប៉ុននេះគឺជាកត្តាយ៉ាងចម្បងក្នុងការធ្វើឱ្យមួយនេះដើរទាន់សម័យកាល។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទសិទ្ធិនិងករណីយកិច្ចក្រោយការលែងលះក្នុងចំណងអាពាហ៍ពិពាហ៍ យើងខ្ញុំបានធ្វើការបែងចែកជា បី ជំពូកដូចខាងក្រោម៖

ជំពូកទី១៖សញ្ញាណទូទៅនៃការលែងលះ

ជំពូកទី២៖ការកណត់អំណាចមេបាចំពោះកូន

ជំពូកទី៣៖ការបែងចែកទ្រព្យសម្បត្តិ និងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

# ជំពូកទី១
# សញ្ញាណទូទៅនៃការលែងលះ

# ជំពូកទី១
# សញ្ញាណទូទៅនៃការលែងលះ

## ១.១.និយមន័យនៃការលែងលះ

ការលែងលះ ជាមធ្យោបាយមួយនាំឱ្យចំណងអាពាហ៍ពិពាហ៍ស្របច្បាប់មួយត្រូវបានបញ្ចប់ ហើយក៏នាំឱ្យសហព័ទ្ធ និងញាតិរបស់សហព័ទ្ធនោះ លែងជាញាតិរបស់សហព័ទ្ធម្ខាងទៀតផងដែរ។ ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍តាមផ្លូវតុលាការ ដោយតម្រូវឱ្យមានសេចក្តីសម្រេចពីតុលាការ ដើម្បីបញ្ជាក់អំពីការរំលត់ចំណងអាពាហ៍ពិពាហ៍។ សាលក្រម ឬសាលដីកា គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលបានធ្វើក្រោយពេលពិចារណាទៅលើភស្តុតាង ដែលទាក់ទងទៅនឹងបញ្ហាដែលត្រូវសម្រេចក្នុងរឿងវិវាទអាពាហ៍ពិពាហ៍។

ការលែងលះបណ្តាលមកពីការរស់នៅមិនចុះសម្រុងគ្នានូវប្រការណាមួយ ដែលមានមូលហេតុកំណត់ជាក់លាក់ ដែលឈានដល់ការលែងលះ។ ក្រោយពីបានរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ហើយប្រសិនបើសហព័ទ្ធណាមួយយល់ឃើញថា ជីវិតអាពាហ៍ពិពាហ៍របស់ខ្លួនពុំអាចបន្តរស់នៅជាមួយគ្នាតទៅទៀតបានទេ ដោយបានលើកឡើងនូវមូលហេតុមកធ្វើជាសំអាងយ៉ាងច្បាស់លាស់តាមបញ្ញត្តិដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ។

## ១.២.ប្រភេទនៃការលែងលះ

ប្តីប្រពន្ធ អាចធ្វើការលែងលះគ្នាដោយមានការព្រមព្រៀងគ្នាទាំងសងខាងដោយគ្មានកំហុសរបស់ប្តី ឬប្រពន្ធណាម្នាក់ឡើយ។ ផ្ទុយទៅវិញក៏មានប្តី ឬប្រពន្ធខ្លះ បានបង្កើតកំហុសជារឿយៗ ដោយការអត់ទ្រាំពុំបានរបស់ភាគីណាម្ខាងពួកគេក៏បានដាក់ពាក្យបណ្តឹងសុំលែងលះ។ ហេតុនេះហើយបានគេបែងចែកការលែងលះជាពីរប្រភេទ គឺការលែងលះដោយមានការព្រមព្រៀង និងការលែងលះដោយមិនមានការព្រមព្រៀង។

### ១.២.១.ការលែងលះដោយការព្រមព្រៀង

ការលែងលះដោយការព្រមព្រៀង គឺជាការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ដោយមានការយល់ព្រមរវាងភាគីទាំងសងខាងនៃចំណងអាពាហ៍ពិពាហ៍ ប៉ុន្តែតុលាការអាចឱ្យលែងលះគ្នាបានក្រោយពីបានយល់ឃើញថាភាគីទាំងសងខាងមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍។[1] ពោលគឺជាការលែងលះដែលកើតចេញពីឆន្ទៈទាំងទ្វេភាគីដោយមិនមានភាគីណាបង្ខំភាគីណាម្នាក់ឡើយ គឺជាការយល់ឃើញពីគូភាគីថាចំណងអាពាហ៍ពិពាហ៍របស់គេត្រូវបានបញ្ចប់ នឹងមិនអាចបដិទានបានឡើយ។ ការលែងលះ

[1]ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៧៩ (ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

ដោយការព្រមព្រៀង គឺត្រូវធ្វើឡើងដោយដាក់ពាក្យសុំទៅតុលាការ។[2] ហើយតុលាការសម្រេចសេចក្តីក្រោមរូបភាពជាដីកាសម្រេច។[3]

### ១.២.២.ការលែងលះដោយពុំមានការព្រមព្រៀង

ការលែងលះដោយពុំមានការព្រមព្រៀង គឺជាការលែងលះដែលសហព័ទ្ធម្ខាងអាចធ្វើការសម្រេចចិត្តសុំប្តឹងលែងលះពីសំណាក់សហព័ទ្ធម្ខាងទៀតដោយឯកឯងបាន ក្នុងករណីដែលរកឃើញនូវកំហុសរបស់ភាគីណាម្ខាង។ ការលែងលះដោយពុំមានការព្រមព្រៀង គឺជាការទាមទារឱ្យលែងលះដោយឆន្ទៈរបស់ភាគីម្ខាងនៃទំនាក់ទំនងអាពាហ៍ពិពាហ៍ ដោយផ្អែកលើមូលហេតុដែលបានកំណត់ដោយច្បាប់។ ហេតុនេះក្នុងករណីមូលហេតុតាមផ្លូវច្បាប់ពុំត្រូវបានទទួលស្គាល់ទេនោះ តុលាការក៏មិនអាចសម្រេចឱ្យលែងលះបានដែរ។

ការលែងលះដោយមិនមានការព្រមព្រៀង ភាគីទាមទារឱ្យលែងលះត្រូវទទួលបន្ទុកបញ្ជាក់នូវអង្គហេតុនីមួយៗដែលជាមូលហេតុនៃការលែងលះ ដើម្បីឱ្យតុលាការសម្រេចឱ្យលែងលះ។

ប្រសិនបើភាគីមិនមានឆន្ទៈព្រមព្រៀងគ្នាក្នុងការលែងលះទេ ការលែងលះអាចអនុវត្តទៅបាន លុះត្រាតែមានមូលហេតុដែលមានចែងច្បាស់លាស់តាមមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណីដែលបញ្ញត្តិអំពីមូលហេតុនៃការលែងលះដូចតទៅ៖

#### ១.២.២.១.ការបានប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ

ការប្រព្រឹត្តអំពើផិតទៅលើសហព័ទ្ធ គឺជាការរួមសវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន។[4] អំពើផិតក្បត់នេះ ក្រៅពីមូលហេតុដែលសហព័ទ្ធអាចសុំលែងលះតាមក្រមរដ្ឋប្បវេណីបានហើយ នោះភាគីដែលប្រព្រឹត្តអំពើផិតក្បត់ ក៏ត្រូវបានចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌផងដែរ ប្រសិនបើសហព័ទ្ធណាម្ខាងបានប្តឹង ដោយត្រូវផ្តន្ទាទោសតាមមាត្រា១០ នៃច្បាប់ស្តីពីឯកពន្ធភាព ឆ្នាំ២០០៦។ ទោសដែលត្រូវអនុវត្តទៅលើការប្រព្រឹត្តទៅលើអំពើផិតក្បត់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ខែ ដល់១ (មួយ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ពីររយពាន់) រៀល ដល់១.០០០.០០០ (មួយលាន)រៀល។[5] ចំពោះការទាមទារលែងលះដោយមូលហេតុខាងលើ

---

[2]ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០, តារាងឧបសម្ព័ន្ធ ផ្នែកទី៤ ចំណុចទី៥ (ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង)។

[3]ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង, មាត្រា៣។

[4]សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ៣, ទំព័រទី២០ រៀបរៀងដោយ ក្រុមការងារនៃគ្រូបង្គោលនៃសាលាភូមិន្ទចៅក្រម ការកែសម្រួលលើការបោះពុម្ពលើកទី១, ភ្នំពេញ មីនា ២០១៧ និង ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦, មាត្រា៧។

[5]ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦, មាត្រា១០។

នេះ សហព័ទ្ធត្រូវបញ្ជាក់អំពីអង្គហេតុនៃការផិតក្បត់ ដោយមានការថតជាវីដេអូ ឬរូបភាពជាអាទិ៍ ដែលបង្ហាញអំពីការផិតក្បត់របស់សហព័ទ្ធម្ខាងទៀត ដូចជាសហព័ទ្ធម្ខាងទៀតមានទំនាក់ទំនងផ្លូវភេទជាមួយបុគ្គលដទៃក្រៅពីសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ អង្គហេតុនេះអាចចាត់ថាជាអំពើផិតក្បត់ នោះតុលាការនឹងពិចារណាឱ្យធ្វើការលែងលះបាន។

**១.២.២.២.ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ**

ការបោះបង់សហព័ទ្ធចោលដោយគ្មានមូលហេតុត្រឹមត្រូវ គឺជាការដែលមិនរួមរស់ជីវភាពជាមួយគ្នា មិនសហការគ្នា មិនជួយសង្គ្រោះគ្នាទៅវិញទៅមក ហើយដែលគេអាចទទួលស្គាល់ថា ភាគីមិនមានឆន្ទៈបន្តជីវភាពរស់នៅជាមួយគ្នាទៅមុខទៀតឡើយ។

**១.២.២.៣.ការមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ**

បើមិនដឹងច្បាស់ថាសហព័ទ្ធស្លាប់ ឬរស់អស់រយៈពេលជាង១ឆ្នាំ ប្រសិនបើសហព័ទ្ធណាម្ខាងបានចាកចេញ ឬចុះចោលសហព័ទ្ធម្ខាងទៀតដោយបាត់ដំណឹងសូន្យឈឹង មិនផ្តល់ដំណឹងឱ្យសហព័ទ្ធម្ខាងទៀតបានដឹងមានរយៈពេលជាង១ឆ្នាំ សហព័ទ្ធម្ខាងទៀតនោះអាចដាក់ពាក្យសុំលែងលះ ឬជូនដំណឹងទៅឃុំ ឬសង្កាត់ឱ្យបានដឹងពីរឿងនេះបាន។

**១.២.២.៤.សហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់**

កាលបើសហព័ទ្ធបានរស់នៅបែកគ្នាជាបន្តបន្ទាប់ដោយមិនបានរស់នៅជាមួយគ្នាសោះ អស់រយៈពេលជាង១ឆ្នាំ ទោះបីជាបានដឹងដំណឹងពីគ្នាក៏ដោយ ដែលទាំងនេះផ្ទុយទៅនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ នោះសហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យបណ្តឹងសុំលែងលះបាន។ ក៏ប៉ុន្តែចំពោះការរស់នៅឆ្ងាយ ដោយសារការងារមិនចាត់ចូលទៅក្នុងស្ថានភាពនេះទេ។

**១.២.២.៥. ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់**

ករណីផ្សេងទៀតដែលអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ នៅត្រង់ចំណុចនេះក្រមរដ្ឋប្បវេណីគ្រាន់តែកំណត់ជាលក្ខណៈទូលាយពីមូលហេតុនៃការលែងលះ ដោយទុកឱ្យចៅក្រមជាអ្នកវាយតម្លៃកំណត់ថា តើករណីណាខ្លះដែលឱ្យយើងជឿជាក់ថា អាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន។ ជាក់ស្តែង នៅក្នុងករណីនេះអាចមានច្រើន ដោយរួមបញ្ចូលទាំងការប្រើអំពើហិង្សាទៅលើសហព័ទ្ធ (ហិង្សាផ្លូវកាយ ផ្លូវចិត្ត ជំងឺ ជាអាទិ៍)។

មូលហេតុទាំងឡាយដែលបានរៀបរាប់មកនេះ សុទ្ធតែជាមូលហេតុដែលនាំឱ្យតុលាការធ្វើការសម្រេចចិត្តកាត់ផ្តាច់ចំណងអាពាហ៍ពិពាហ៍របស់សហព័ទ្ធ តែទោះជាយ៉ាងណាក៏ដោយតុលាការនៅតែច្រានចោលការទាមទារនេះបាន ប្រសិនបើ៖

–ការលែងលះនឹងបណ្តាលឱ្យការទ្រទ្រង់ជីវភាពរបស់សហព័ទ្ធ ឬកូនក្រលំបាកយ៉ាងខ្លាំង ឬបើការលែងលះនឹងបណ្តាលឱ្យមានការឈឺចាប់មិនអាចទ្រាំទ្របាន[6]។ ឧបមាថា លោកចំណាន និង លោកស្រីសុខា បានរៀបការជាមួយគ្នានៅឆ្នាំ២០១០ ។ នាពេលថ្មីៗនេះ លោកស្រីសុខាមានបញ្ហាផ្នែកសុខភាព ហើយតែងតែរករឿងឈ្លោះប្រកែកជាមួយនឹងលោកចំណាន ដែលរហូតដល់ពេលខ្លះ លោកស្រីសុខា បានជេរបញ្ចោរលោកចំណាន ទៀតផង។ បន្ទាប់មកលោកចំណាន បានដាក់ពាក្យបណ្តឹងលែងលះ ហើយលោកស្រីសុខា មិនយល់ព្រមនឹងការលែងលះនេះទេ។ អ្នកទាំងពីរមានកូនពីរនាក់ ម្នាក់អាយុ១ឆ្នាំ និង ម្នាក់ទៀតទើបតែមានអាយុ ២ឆ្នាំប៉ុណ្ណោះ។ លោកស្រីសុខា មិនមានការងារធ្វើទេហើយនាងក៏មានជំងឺផ្លូវចិត្តប្រចាំកាយទៀត ចំណែកឯទ្រព្យសម្បត្តិរួមក៏ពុំមានច្រើននោះដែរ។ ប្រសិនបើតុលាការយល់ឃើញថា ការឱ្យអ្នកទាំងពីរលែងលះពីគ្នានឹងធ្វើឱ្យលោកស្រី សុខា មិនអាចទ្រាំទ្រនឹងការឈឺចាប់នេះ រួមផ្សំជាមួយនឹងស្ថានភាពសុខភាពនាងទន់ខ្សោយផងនោះ តុលាការអាចច្រានចោលការទាមទារលែងលះរបស់លោកចំណានបាន។

–ការទាមទារលែងលះផ្ទុយនឹងភាពសុចរិត ដោយជនដែលទាមទារឱ្យលែងលះគ្នានោះធ្វេសប្រហែលយ៉ាងខ្លាំង ក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធ[7]។ ក្នុងករណីមួយទៀតលោកស្រី ភារី និងលោក ករុណា បានរៀបការជាមួយគ្នានៅឆ្នាំ ២០០០ ហើយមានកូនពីរនាក់សុទ្ធតែជាអនីតិជន។ លុះដល់ឆ្នាំ២០០៥ ដោយសារតែការអាក់អន់ស្រពន់ចិត្តបន្តិចបន្តួច លោក ករុណា បានជួបនឹងនារីម្នាក់ផ្សេងទៀត ហើយក៏រួមរស់នៅជាមួយនឹងនារីនោះ ដោយមិនបានជួយផ្គត់ផ្គង់ជីវភាពរបស់លោកស្រី ភារី និង កូនឡើយ។ រហូតដល់ឆ្នាំ២០១៣ លោក ករុណា បានដាក់ពាក្យបណ្តឹងលែងលះពីលោកស្រី ភារី។ ក្នុងករណីនេះ លោក ករុណា និងលោកស្រី ភារី បានរស់នៅបែកគ្នាអស់រយៈពេល ៨ឆ្នាំ ទៅហើយដូច្នេះ គឺមានមូលហេតុនៃការលែងលះ។ ក៏ប៉ុន្តែក្នុងករណីខាងលើលោក ករុណា ជាអ្នកចុះចេញពីផ្ទះ ហើយក៏ជាអ្នកទាមទារលែងលះទៀត ដូច្នេះបានសេចក្តីថាលោក ករុណា យកមូលហេតុនៃការបែកលំនៅពីគ្នាដែលបង្កឡើងដោយលោក ករុណា ខ្លួនឯងមកធ្វើជាសំអាងដើម្បីលែងលះហើយម្យ៉ាងវិញទៀតលោក ករុណា ក៏មិនបានជួយផ្គត់ផ្គង់ដល់លោកស្រីភារី និងកូនទាំងពីរនាក់ជាអនីតិជនផងដែរ។ ដោយផ្អែកលើស្ថានភាពបែបនេះ តុលាការអាចច្រានចោលការទាមទារលែងលះបាន។

[6] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៨ កថាខណ្ឌទី២។

[7] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៨ កថាខណ្ឌទី៣។

# ជំពូកទី២

# ការកំណត់អំណាចមេបាចំពោះកូន

# ជំពូកទី២
# ការកំណត់អំណាចមេបាចំពោះកូន

## ២.១.អ្នកមានអំណាចមេបា

អំណាចមេបា គឺជាសិទ្ធិ និងករណីយកិច្ចក្នុងការបីបាច់ថែរក្សាកូន ដែលជាអនីតិជន និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូននោះ។[៩] មានន័យថាអំណាចមេបា គឺផ្តើមចេញពីទំនាក់ទំនងរវាងឪពុកម្តាយ និងកូន ដែលឪពុកម្តាយមានករណីយកិច្ច ក្នុងការបីបាច់ថែរក្សា និងគ្រប់គ្រងកូន ។

ជាគោលការណ៍ អ្នកដែលមានអំណាចមេបា គឺឪពុកម្តាយបង្កើតតែប៉ុណ្ណោះ ដែលមានករណីយកិច្ចក្នុងចិញ្ចឹមបីបាច់ថែរក្សា និងគ្រប់គ្រងកូន។ ប៉ុន្តែករណីចំណងអាពាហ៍ពិពាហ៍របស់ឪពុកម្តាយត្រូវរលាយនោះនឹងនាំឱ្យមានការកំណត់អ្នកដែលមានអំណាចមេបាលើកូន ដោយកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានអំណាចមេបាលើកូន។

### ២.១.១.អ្នកមានអំណាចមេបា

#### ២.១.១.១.អំណាចមេបារួម

តាមរយៈក្រមរដ្ឋប្បវេណី ពុំមានបទប្បញ្ញត្តិណាមួយចែងអំពីការកំណត់អំណាចមេបារួមក្រោយការលែងលះឡើយ ហើយបញ្ញត្តិច្បាប់ក៏ពុំហាមថាតុលាការមិនអាចកំណត់អំណាចមេបារួម នៅពេលដែលឪពុកម្តាយលែងលះគ្នា។ រីឯការអនុវត្តជាក់ស្តែងតុលាការមិនធ្លាប់សម្រេចអំពីអ្នកមានអំណាចមេបារួមលើកូនឡើយ ដោយតុលាការសម្រេចដោយយោងតាមបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណី។

មូលហេតុដែលក្រមរដ្ឋប្បវេណី មិនកំណត់យកអំណាចមេបារួមមកអនុវត្តក្នុងករណីលែងលះ ដោយសារតែការប្រគល់អំណាចមេបាទៅឪពុក និងម្តាយដែលបានលែងលះគ្នា អាចធ្វើឱ្យមានឧបសគ្គដល់ការអនុវត្តអំណាចមេបានេះផងដែរ។ ដូច្នេះហើយ ទើបក្រមកំណត់យកអំណាចមេបាទោល ហើយក៏បានផ្តល់ឱ្យមានការសម្របសម្រួលមួយចំនួន ដោយបញ្ញត្តឱ្យមានអ្នកដែលមានអំណាចមេបាផ្តល់សិទ្ធិ និងករណីយកិច្ចខ្លះដល់ឪពុក ឬម្តាយដែលមិនមែនជាអ្នកដែលមានអំណាចមេបា។ មួយវិញទៀត ទោះបីជាឪពុក ឬម្តាយណាម្នាក់ដែលជាអ្នកដែលមានអំណាចមេបាលើកូនក៏ដោយ ក៏ឪពុក ឬម្តាយនោះនៅតែជាឪពុក ឬម្តាយតាមផ្លូវច្បាប់ និងមិនបាត់បង់នូវទំនាក់ទំនងគតិយុត្តរវាងឪពុក ឬម្តាយនឹងកូនឡើយ។

#### ២.១.១.២.អំណាចមេបាទោល

អំណាចមេបាទោល អនុវត្តក្នុងករណីលែងលះដែលតុលាការចាំបាច់ត្រូវកំណត់យកឪពុក ឬម្តាយណាម្ខាងជាអ្នកមានសិទ្ធិអំណាចមេបា។

[៩]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៤។

មួយវិញទៀត ក្នុងករណីដែលឪពុកម្តាយលែងលះគ្នានៅមុនកំណើតរបស់កូន ម្តាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលកើតមកនោះ ប៉ុន្តែនៅក្រោយកំណើតរបស់កូនអាចកំណត់យកឪពុកជាអ្នកមានអំណាចមេបាបាន តាមការពិភាក្សារបស់ឪពុកម្តាយ ឬតាមសេចក្តីសម្រេចរបស់តុលាការ។ ដោយតុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូន។[១]

**២.១.២.ការកំណត់អ្នកមានអំណាចមេបាក្រោយលែងលះ**

**២.១.២.១.អំណាចមេបាកំណត់ការព្រមព្រៀង**

ការព្រមព្រៀងពីអ្នកមានអំណាចមេបាចំពោះកូន មានលក្ខណៈដូចគ្នានឹងចំណុចព្រមព្រៀងអំពីទ្រព្យដែរ ព្រោះថាបើភាគីមានការព្រមព្រៀងនាំឱ្យមិនចំណុចវិវាទទេ ដូច្នេះតុលាការនឹងធ្វើការសម្រេចតាមការព្រមព្រៀងនោះ។ អំណាចមេបាអាចធ្វើការព្រមព្រៀងក្រៅតុលាការ ឬក្នុងនីតិវិធីតុលាការក៏បានដោយនៅក្នុងករណីលែងលះតាមពាក្យសុំ ភាគីអាចធ្វើការកំណត់អ្នកមានអំណាចមេបាក្រៅនីតិវិធីតុលាការ និងការកំណត់អ្នកមានអំណាចមេបាក្នុងនីតិវិធីតុលាការ។

**ក.ការកំណត់អ្នកមានអំណាចមេបាក្រៅនីតិវិធីតុលាការ**

ដើម្បីឱ្យការលែងលះតាមពាក្យសុំដំណើរការទៅបាន ក្នុងករណីដែលភាគីទាំងពីរមានកូនជាអនីតិជន ចាំបាច់ត្រូវតែកំណត់អំពីអ្នកមានអំណាចមេបាចំពោះកូនជាមុនសិន។ ដោយហេតុថា នៅរាល់ពេលផ្តាច់ចំណងអាពាហ៍ពិពាហ៍ អំណាចមេបាលើកូនមិនអាចប្រព្រឹត្តទៅដោយសហការគ្នាបានទៀតទេ ដូច្នេះប្រាកដណាស់កូន គឺជាអ្នកដែលត្រូវរងគ្រោះ។ ដូច្នេះហើយ ទើបការសម្រេចអំពីអ្នកមានអំណាចមេបានៅក្នុងពាក្យសុំពិតជាមានសារៈសំខាន់ ដែលបានផ្តល់នូវផលប្រយោជន៍យ៉ាងខ្លាំងទៅដល់កូនជាអនីតិជន។

កិច្ចព្រមព្រៀងកំណត់អ្នកមានអំណាចមេបានៅក្រៅនីតិវិធីតុលាការ គឺគូភាគីនៃពាក្យសុំលែងលះអាចធ្វើការព្រមព្រៀងគ្នាតាមរយៈកិច្ចព្រមព្រៀងដែលធ្វើឡើងជាលាយលក្ខណ៍អក្សរបាន។ ដោយការព្រមព្រៀងជាលាយលក្ខណ៍អក្សរក្រៅនីតិវិធីតុលាការ មានខ្លឹមសារព្រមព្រៀងគ្នាលើចំណុចអំណាចមេបា ដែលត្រូវមានការចូលរួមយ៉ាងសំខាន់ពីភាគីប្តី និងប្រពន្ធ។ កិច្ចព្រមព្រៀងមានលក្ខណៈជាក់លាក់មួយ និងច្បាស់លាស់ ដែលស្តែងចេញពីឆន្ទៈពិតប្រាកដរបស់គូភាគី។ ការព្រមព្រៀងដែលកើតចេញពីឆន្ទៈរបស់ភាគីទាំងពីរ គឺមានគោលបំណងដើម្បីស្នើសុំឱ្យតុលាការធ្វើការកំណត់អំពីអ្នកមានអំណាចមេបាតាមការព្រមព្រៀង។ ជាក់ស្តែងបើមានការព្រមព្រៀងគ្នានៅក្រៅនីតិវិធីតុលាការ ដោយឱ្យប្រពន្ធជាអ្នកមានអំណាចមេបាចំពោះកូន ដូច្នេះនៅពេលដែលដាក់ពាក្យសុំលែងលះមកតុលាការ យើងអាចស្នើសុំឱ្យតុលាការកំណត់តាមអ្វីដែលយើងបានព្រមព្រៀងគ្នានោះហើយនៅក្នុងសេចក្តីសម្រេចបញ្ចប់តុលាការនឹងធ្វើការសម្រេចទៅតាមអ្វីដែលភាគីបានព្រមព្រៀងគ្នា។

**ខ.ការកំណត់អ្នកមានអំណាចមេបាក្នុងនីតិវិធីតុលាការ**

[១]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៧ កថាខណ្ឌទី២ និងកថាខណ្ឌទី៣។

ក្នុងការលែងលះតាមពាក្យសុំ ក្រៅអំពីការកំណត់អំណាចមេបាចំពោះកូនដែលជាអនីតិជនក្រៅនីតិវិធីតុលាការគេក៏អាចធ្វើការកំណត់ក្នុងនីតិវិធីបានដែរ ដោយភាគីនៃពាក្យសុំធ្វើការព្រមព្រៀងគ្នាបានដែលមានការកំណត់សរសេរនៅក្នុងពាក្យសុំនោះតែម្តង ដើម្បីសុំឱ្យតុលាការធ្វើការសម្រេចតាមអ្វីដែលសហព័ទ្ធបានព្រមព្រៀង។ ជាក់ស្តែងក្នុងនីតិវិធីនៃកិច្ចសាកសួរ បើការសាកសួរបញ្ជាក់ថាគូភាគីពិតជាមានការព្រមព្រៀងគ្នាដោយពិតប្រាកដដូចដែលមានសរសេរក្នុងពាក្យសុំមែន តុលាការនឹងធ្វើការកំណត់អំពីអ្នកមានអំណាចមេបាតាមការព្រមព្រៀង តាមរយៈសេចក្តីសម្រេចបញ្ចប់ ឬដីកាសម្រេច។

#### ២.១.២.២. ការកំណត់អំណាចមេបាក្នុងករណីលែងលះតាមឆន្ទានុសិទ្ធិរបស់តុលាការ

ករណីគ្មានការព្រមព្រៀងគ្នាអំពីអំណាចមេបា តុលាការត្រូវសម្រេចអំពីអ្នកមានអំណាចមេបា ដែលជាឪពុក ឬម្តាយ ផ្អែកលើឧត្តមប្រយោជន៍កូន ជាទូទៅតុលាការពិចារណាអំពីផលប្រយោជន៍កូនៈ

– ស្ថានភាពរបស់ឪពុក ឬម្តាយ ដូចជា លទ្ធភាពក្នុងការគ្រប់គ្រង (អាយុ និងស្ថានភាពសុខភាពជាដើម) សេដ្ឋកិច្ច( មុខរបរ ប្រាក់ចំណូលដើម្បីធានាដល់ការចិញ្ចឹមបីបាច់រក្សានិងអប់រំកូន មានឬគ្មានលំនៅឋាន) ស្ថានភាពគ្រប់គ្រងកូន ( មានឬគ្មានជំនួយពីសាច់ញាតិ) ការផ្តល់ក្តីស្រឡាញ់ចំពោះកូនជាអាទិ៍ដែលធ្លាប់មានកន្លងមក។

– ស្ថានភាពរបស់កូន ដូចជា អាយុ ស្ថានភាពនៃការលូតលាស់ រាងកាយ និង ចិត្តគំនិតឆន្ទៈរបស់កូន ភាពជិតស្និតនៃចំណងរវាងឪពុកម្តាយ និងសាច់ញាតិជាដើម។

បើតុលាការមើលឃើញថា ឪពុក ឬម្តាយណាមួយ មានស្ថានភាពមានវ័យចំណាស់ សុខភាពរាងកាយទ្រុឌទ្រោម គ្មានគិតគូរធ្វើការរកស៊ី គ្មានផ្ទះសំបែងត្រឹមត្រូវ ឬធ្លាប់ប្រើហិង្សាលើកូន តុលាការនឹងមិនឱ្យឪពុក ឬម្តាយនោះជាអ្នកមានអំណាចមេបាលើកូនទេ តុលាការប្រាកដជាឱ្យអំណាចមេបាទៅបុគ្គលដែលមានស្ថានភាពមានការងារច្បាស់លាស់ មានផ្ទះសម្បែងត្រឹមត្រូវ មានអត្តចរិតសមរម្យ មានការយកចិត្តទុកដាក់ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូន។ ដើម្បីកំណត់ថាតើអ្នកណាដែលមានលក្ខណៈគ្រប់គ្រាន់ជាអ្នកមានអំណាចមេបា ហេតុនេះ តុលាការត្រូវថ្លឹងថ្លែងដោយឆន្ទានុសិទ្ធិរបស់ខ្លួនអំពីលទ្ធភាពរវាងឪពុកម្តាយ ដែលអាចផ្តល់ប្រយោជន៍ឱ្យកូនច្រើនជាងគេ។

## ២.២. ករណីយកិច្ចអ្នកមានអំណាចមេបា និងអ្នកពុំមានអំណាចមេបា

### ២.២.១.សិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា

នៅក្នុងក្រមរដ្ឋប្បវេណីបានបញ្ញត្តនូវករណីយកិច្ចមួយចំនួន ដែលតម្រូវឱ្យអ្នកដែលត្រូវបានកំណត់ថាជាអ្នកមានអំណាចមេបា មានសិទ្ធិ និងករណីយកិច្ចគោរពតាមក្នុងអំឡុងពេលអនុវត្តសិទ្ធិជាអ្នកមានអំណាចមេបាចំពោះកូន។

**២.២.១.១.សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងកូន**

ករណីយកិច្ចទាក់ទាងនឹងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវមានរហូតដល់កូនដល់នីតិភាព គឺជាតួនាទីរបស់អ្នកមានអំណាចមេបា។ ករណីយកិច្ចទាក់ទាងនឹងកូនមានដូចជា ការអប់រំកូន ការបីបាច់ថែរក្សារូបកាយកូន ការដាក់ទណ្ឌកម្មកូន ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម និងការទាមទារឱ្យប្រគល់កូន។

**ក.ការបីបាច់ថែរក្សារូបកាយកូន**

រាល់សកម្មភាពទាំងឡាយដែលចាំបាច់សម្រាប់ការលូតលាស់និងការពារកូនដែលជាអនីតិជន រួមទាំងការផ្តល់ចំណីអាហារ សម្លៀកបំពាក់ ទីសំណាក់ ការផ្តល់ការថែទាំវេជ្ជសាស្ត្រ ការឱ្យកូនចូលរៀន និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងកូនដែលជាអនីតិជនមិនឱ្យប្រព្រឹត្តបទល្មើស និងអំពើមិនត្រឹមត្រូវ។[10]

**ខ. ការអប់រំកូន**

អ្នកមានអំណាចមេបា មានតួនាទីធានានូវការជំរុញការអភិវឌ្ឍខាងបញ្ញារបស់កូន និងផ្តល់ឱ្យកូនទទួលបាននូវចំណេះដឹង និងជំនាញដែលចាំបាច់សម្រាប់ដឹកនាំជីវិតនៅក្នុងសង្គម ហើយការអប់រំនោះសំដៅទាំងការអប់រំក្នុងផ្ទះ និងសាលារៀន។[11]

**គ.ការដាក់ទណ្ឌកម្មកូន**

ដើម្បីអប់រំកូន អ្នកមានអំណាចមេបាមានសិទ្ធិក្នុងការដាក់ទណ្ឌកម្មកូនដោយខ្លួនឯង នៅពេលដែលកូនប្រព្រឹត្តអំពើប្រឆាំងនឹងសង្គម ឬអំពើដែលពុំគប្បី ប៉ុន្តែការដាក់ទណ្ឌកម្មនោះក្នុងទំហំដែលចាំបាច់សម្រាប់ការអប់រំដល់កូនតែប៉ុណ្ណោះ។[12] ប៉ុន្តែប្រសិនបើអ្នកមានអំណាចមេបាដាក់ទណ្ឌកម្មកូនហួសកម្រិតនូវទំហំចាំបាច់ដែលធ្វើឱ្យកូនរងគ្រោះដល់ផ្លូវកាយ ឬផ្លូវចិត្ត តុលាការអាចប្រកាសព្យួរ ឬដកហូតអំណាចមេបាបាន។[13] ជាក់ស្តែងក្នុងករណីកូនដើរលេងមិនចូលរៀន បុរសជាឪពុកបានដាក់ទណ្ឌកម្មកូនមិនឱ្យចេញពីបន្ទប់នៅក្នុងផ្ទះរយៈពេល១ថ្ងៃពេញ។ ប៉ុន្តែ ប្រសិនបើករណីបង្ខាំងកូនដោយមិនឱ្យចំណីអាហាររហូតដល់ទៅរាប់ខែវិញនោះ ចាត់ទុកថា ហួសពីទំហំចាំបាច់។

**ឃ.ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម**

អនីតិជនអាចប្រកបវិជ្ជាជីវៈ ឬធ្វើអាជីវកម្មបាន លុះត្រាតែមានការអនុញ្ញាតពីអ្នកមានអំណាចមេបារបស់ខ្លួន។ ផ្ទុយទៅវិញ ប្រសិនបើពុំមានការយល់ព្រមពីអ្នកមានអំណាចមេបា កូនមិនអាចប្រកបវិជ្ជាជីវៈ ឬធ្វើអាជីវកម្មបានឡើយ ហើយអ្នកមានអំណាចមេបា ក៏អាចកម្រិតនូវការអនុញ្ញាត ឬ ការលុបចោលនូវការអនុញ្ញាត

[10]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៤ ។

[11]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤៣ ។

[12]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤៥។

[13]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤៨។

នោះផងដែរ។[14] អ្នកមានអំណាចមេបា អាចលុបចោលសកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រម លើកលែងតែចំពោះសកម្មភាពទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[15] ទោះបីជាអ្នកមានអំណាចមេបាមានសិទ្ធិធ្វើសកម្មភាពតំណាងឱ្យកូនក៏ដោយ ហើយសកម្មភាពរបស់អ្នកមានអំណាចមេបាបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាសកម្មភាពរបស់កូន អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូននោះដែរ។

**ខ.ការទាមទារឱ្យប្រគល់កូន**

អ្នកមានអំណាចមេបាអាចទាមទារឱ្យប្រគល់កូន ពីអ្នកដែលបានដាក់កូនក្នុងស្ថានភាពខុសច្បាប់ ដូចជា កូនត្រូវបានពង្រត់ ឬកូនត្រូវបានបង្ខាំងទុកជាដើម ព្រមទាំងករណីបុគ្គលដែលត្រូវបានឱ្យមើលថែទាំកូនជាបណ្ដោះអាសន្ន តាមរយៈកិច្ចសន្យា បុគ្គលដែលត្រូវទទួលខុសត្រូវលើកូនជាបណ្ដោះអាសន្នតាមរយៈកិច្ចសន្យានោះ បានខកខានក្នុងការប្រគល់កូនមកវិញដោយបំពានកិច្ចសន្យា ដោយសារវាជាការរំលោភអំណាចមេបាក្នុងការយកកូនទៅបីបាច់រក្សារូបកាយ និងចិញ្ចឹម។ អ្នកមានអំណាចមេបាអាចទាមទារសំណងការខូចខាតពីតតិយជនដោយសារការរំលោភលើអំណាចមេបានោះក្លាយជាអំពើអនីត្យានុកូល ហើយក៏ត្រូវបានអនុញ្ញាតឱ្យសម្រេចសិទ្ធិទាមទារឱ្យប្រគល់កូន តាមរយៈការបង្ខំដោយផ្ទាល់បានផងដែរ។[16]

ដោយឡែកករណីដែលឪពុកម្ដាយបានលែងលះគ្នា ហើយឪពុក ឬម្ដាយណាម្ខាងត្រូវបានកំណត់ជាអ្នកដែលមានអំណាចមេបា ប៉ុន្តែឪពុក ឬម្ដាយម្ខាងទៀតមិនព្រមប្រគល់កូន ឬ ករណីដែលឪពុកម្ដាយចិញ្ចឹមបានក្លាយជាអ្នកដែលមានអំណាចមេបា ប៉ុន្តែឪពុកម្ដាយបង្កើតដែលមិនមានអំណាចមេបា មិនព្រមប្រគល់កូនឱ្យឪពុកម្ដាយចិញ្ចឹមជាដើម។ ប្រសិនបើអនីតិជនដែលមានសមត្ថភាពខាងឆន្ទៈរបស់ខ្លួនផ្ទាល់ ឆន្ទៈរបស់កូននោះមិនគួរត្រូវបានអើពើទាំងស្រុងទេ ដូច្នេះអ្នកមានអំណាចមេបា និងឪពុកម្ដាយ ដែលពុំអំណាចមេបា ត្រូវពិភាក្សាគ្នាដើម្បីដោះស្រាយបញ្ហានេះ។[17] មានករណីមួយ លោក ដារ៉ា និង អ្នកស្រី នូ បានលែងលះគ្នាដោយតុលាការបានសម្រេចប្រគល់អំណាចមេបាលើកូនឈ្មោះ សី អាយុ៥ឆ្នាំ ឱ្យទៅលោកដារ៉ា។ ប៉ុន្តែដោយហេតុថា អ្នកស្រី នូ មានសេចក្ដីនឹករលឹកកូនខ្លាំងពេក នាងបានសម្រេចចិត្តយកកូនឈ្មោះ សី មកថែរក្សានៅផ្ទះរបស់នាង ដោយមិនព្រមប្រគល់

---

[14]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា២០ និង មាត្រា១០៤៦។

[15]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១៨។

[16]គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី, សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ៥, គន្ថី៧ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌,២០១០), មាត្រា១០៤៧ កថាខណ្ឌទី១ (ចាប់ពីពេលនេះទៅហៅថា សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី)។

[17]សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រា១០៤៧ កថាខណ្ឌទី២។

ឱ្យលោក ដារ៉ា វិញទេ។ ក្នុងករណីនេះ លោក ដារ៉ា ជាអ្នកមានអំណាចមេបាលើកូន ដូច្នេះ គាត់អាចទាមទារឱ្យលោកស្រី នូ ប្រគល់កូនឱ្យគាត់វិញបានតាមផ្លូវច្បាប់។

### ២.២.១.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង

អ្នកមានអំណាចមេបាមានសិទ្ធិ និងករណីយកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន និងក្នុងការតំណាងឱ្យកូននោះ ចំពោះសកម្មភាពដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ។ ការតំណាងនោះ ហៅថា ការតំណាងដែលច្បាប់បានកំណត់។[18] មានន័យថា ជាធម្មតា កូនជាអនីតិជនពុំមានទ្រព្យសម្បត្តិច្រើនទេ ទ្រព្យសម្បត្តិដែលអនីតិជនអាចទទួលបាន គឺតាមរយៈសន្តតិកម្ម ប្រទានកម្ម សំណងនៃការខូចខាតជាអាទិ៍។ ម្យ៉ាងវិញទៀត ដោយសារកូនជាអនីតិជន ដែលពុំមានសមត្ថភាពពេញលេញក្នុងការធ្វើសកម្មភាព ឬថែរក្សា ឬចាត់ចែងទ្រព្យសម្បត្តិ ដោយខ្លួនឯងឡើយ ទើបច្បាប់កំណត់ថា អ្នកមានអំណាចមេបា មានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ និងតំណាងឱ្យកូន ទាក់ទងនឹងសកម្មភាពទាំងនោះ។ ហេតុនេះ សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានអំណាចមេបា អ្នកមានអំណាចមេបា អាចលុបចោលសកម្មភាពនោះបាន លើកលែងតែសកម្មភាពដែលទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ។[19] ទោះបីជាអ្នកមានអំណាចមេបាមានសិទ្ធិធ្វើសកម្មភាពតំណាងឱ្យកូនក៏ដោយ បើសកម្មភាពរបស់អ្នកមានអំណាចមេបា បង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាកម្មភាពរបស់កូន អ្នកមានអំណាចមេបាត្រូវទទួលការយល់ព្រមពីកូននោះ។

មួយវិញទៀតទោះបីជាអ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនក៏ដោយ បើតតិយជនបានផ្តល់ទ្រព្យសម្បត្តិ ទៅឱ្យកូនដោយបង្ហាញឆន្ទៈថាមិនឱ្យឪពុក ឬម្តាយណាម្ខាងដែលអនុវត្តអំណាចមេបាគ្រប់គ្រងទ្រព្យសម្បត្តិទេ ទ្រព្យសម្បត្តិនោះពុំស្ថិតក្រោមការគ្រប់គ្រងរបស់អ្នកមានអំណាចមេបាឡើយ។ ទោះបីជាតតិយជនបានបង្ហាញឆន្ទៈដូចខាងលើក៏ដោយ ហើយអនីតិជនមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិនេះដោយខ្លួនឯងបានទេ ករណីនេះ បើតតិយជននោះមិនបានកំណត់អ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិនោះទេ តុលាការអាចជ្រើសតាំងអ្នកអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានតាមការទាមទាររបស់កូន ឬញាតិក្នុង៤ថ្នាក់របស់កូន ឬតំណាងអយ្យការ។[20]

ថ្វីបើអ្នកមានអំណាចមេបាមានសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនក៏ដោយ តែមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ឬយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួននូវទ្រព្យសម្បត្តិរបស់កូន សម្រាប់ផលប្រយោជន៍របស់ខ្លួន ឬរបស់តតិយជន ឬគែបន្លំធ្វើឱ្យចុះអន់ថយ សឹករេចរឹល តាមរយៈការគ្រប់គ្រងមិនស្មោះត្រង់ឡើយ ពោលគឺអ្នកមាន

[18] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១។

[19] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៨។

[20] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៨ កថាខណ្ឌទី២។

អំណាចមេបាត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងសុចរិត។[21] ក្នុងករណីអ្នកមានអំណាចមេបាធ្វើសកម្មភាពបំពាន គេអាចព្យួរ ឬដកហូតសិទ្ធិអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិបានតាមផ្លូវតុលាការ។

ម៉្យាងវិញទៀត អ្នកមានអំណាចមេបាមិនត្រូវធ្វើសកម្មភាពដែលផលប្រយោជន៍របស់ខ្លួន និងកូនផ្ទុយគ្នានោះទេដូចជា អ្នកមានអំណាចមេបាទិញអចលនវត្ថុរបស់កូន ឬដាក់អចលនវត្ថុរបស់កូនជាប្រាតិភោគដើម្បីធានាកាតព្វកិច្ចរបស់ខ្លួនជាអាទិ៍។ ក្នុងករណីដែលអ្នកមានអំណាចមេបាមានបំណងធ្វើសកម្មភាពដែលបណ្តាលឱ្យមានភាពផ្ទុយនៃផលប្រយោជន៍រវាងខ្លួននិងកូន អ្នកមានអំណាចមេបាត្រូវទាមទារឱ្យតុលាការជ្រើសតាំងពិសេសសម្រាប់កូន។[22] បើពុំដូច្នេះទេសកម្មភាពដែលអ្នកមានអំណាចមេបាបាន គឺជាការតំណាងដែលគ្មានសិទ្ធិដូចមានចែងនៅក្នុងមាត្រា៣៦៩ នៃក្រមរដ្ឋប្បវេណី ហើយសកម្មភាពនោះពុំបង្កើតអានុភាពចំពោះម្ចាស់សិទ្ធិទេ។

នៅពេលដែលអំណាចមេបាបានបញ្ចប់ជាលទ្ធផល ការគ្រប់គ្រងទាក់ទងនឹងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិក៏ត្រូវបញ្ចប់ដែរ ហើយទាក់ទងនឹងការបញ្ចប់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន អ្នកមានអំណាចមេបាត្រូវគណនាចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដោយគ្មានការយឺតយ៉ាវ(អំឡុងពេលសមរម្យដែលឆ្លើយតបនឹងស្ថានភាពជាក់ស្តែង)។ នៅក្នុងអំឡុងពេលនៃការអនុវត្តអំណាចមេបា អ្នកមានអំណាចមេបាបានចំណាយសោហ៊ុយជាច្រើនទាក់ទងនឹងការចិញ្ចឹមកូន រួមទាំងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ប៉ុន្តែការចិញ្ចឹមកូន គឺជាករណីយកិច្ចរបស់អ្នកមានអំណាចមេបា ហេតុនេះពុំសមរម្យឡើយក្នុងការឱ្យកូនបង់សងមកវិញ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ច្បាប់បានកំណត់ថាបើអ្នកមានអំណាចមេបា បានទទួលចំណូលពីទ្រព្យសម្បត្តិរបស់កូន ត្រូវចាត់ទុកថាជាការទូទាត់នឹងសោហ៊ុយចិញ្ចឹមបីបាច់កូន និងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន។ មានន័យថា នៅក្នុងអំឡុងពេលអនុវត្តអំណាចមេបា អ្នកមានអំណាចមេបា អាចអាស្រ័យផលពីទ្រព្យសម្បត្តិរបស់កូនបាន គឺផលដែលទទួលបានពីទ្រព្យសម្បត្តិនោះដូចជា ថ្លៃឈ្នួលជាអាទិ៍ អ្នកមានអំណាចមេបាមិនចាំបាច់ប្រគល់ឱ្យកូននៅពេលដែលកូនមាននីតិភាពទេ។ ផ្ទុយទៅវិញ ចំពោះទ្រព្យសម្បត្តិបានផ្តល់មកពីប្រទានកម្ម ហើយអ្នកផ្តល់ឱ្យនោះបានបង្ហាញឆន្ទៈមិនឱ្យអ្នកមានអំណាចមេបាអាស្រ័យផលពីទ្រព្យសម្បត្តិនោះ ដូចនេះអ្នកមានអំណាចមេបាមិនអាចអាស្រ័យផលពីទ្រព្យសម្បត្តិនោះបានឡើយមានន័យថាចំណូលដែលទទួលបានពីទ្រព្យសម្បត្តិរបស់កូន ត្រូវប្រគល់ឱ្យកូននៅពេលដែលកូនមាននីតិភាព។

ម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកមានអំណាចមេបា បានចាត់ចែងលក់ទ្រព្យសម្បត្តិរបស់កូនជាអាទិ៍នៅពេលដែលកូនមាននីតិភាព ប្រាក់ដែលបានមកពីការលក់នេះត្រូវប្រគល់ឱ្យកូន ប៉ុន្តែប្រសិនបើអ្នកមាន

[21]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៥។

[22]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦៥ កថាខណ្ឌទី១។

អំណាចមេបាមិនបានប្រគល់ប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិរបស់កូនទេ កូនមានសិទ្ធិទាមទារឱ្យអ្នកមានអំណាចមេបាប្រគល់ ដែលអំឡុងពេលនៃការទាមទារនោះគឺ ៣ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់។[23] ក្នុងករណីសិទ្ធិអំណាច ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំទាន់មានអ្នកតំណាងដែលច្បាប់បានកំណត់ (អ្នកមានអំណាចមេបាថ្មី) អំឡុងពេលនៃការទាមទារគឺ ៣ ឆ្នាំ គិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានកាន់តំណែង។[24]

ទោះបីជាអំណាចមេបាបានបញ្ចប់ដោយសារតែកូនបានដល់នីតិភាព ឬសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានព្យួរ ឬដកហូតក៏ដោយ ក៏អ្នកមានអំណាចមេបានៅតែបន្តគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូនដដែល រហូតដល់កូន ឬអ្នកគ្រប់គ្រងថ្មីមានលទ្ធភាពចាប់ផ្ដើមគ្រប់គ្រងទ្រព្យសម្បត្តិនោះ ព្រោះទ្រព្យសម្បត្តិនឹងស្ថិតក្នុងហានិភ័យ បើអ្នកមានអំណាចមេបាលែងគ្រប់គ្រងទ្រព្យសម្បត្តិភ្លាមមុនពេលដែលកូន ឬអ្នកគ្រប់គ្រងថ្មីមិនទាន់មានលទ្ធភាពចាប់ផ្ដើមគ្រប់គ្រងទ្រព្យសម្បត្តិ។[25]

### ២.២.១.២.ការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាចំពោះអំពើអនីត្យានុកូល

អនីតិជន គឺជាជនដែលមានសមត្ថភាពក្នុងការវិនិច្ឆ័យឆន្ទៈមិនគ្រប់គ្រាន់ ហេតុនេះនៅក្រោមគោលការណ៍នៃការទទួលខុសត្រូវចំពោះឆន្ទៈ ប្រសិនបើអនីតិជនបានប្រព្រឹត្តអំពើអនីត្យានុកូល អនីតិជននោះមិនត្រូវទទួលខុសត្រូវអំពើអនីត្យានុកូលទេ។[26]

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាការទទួលខុសត្រូវចំពោះសំណងនៃការខូចខាត ប៉ុន្តែដោយសារអនីតិជនមិនទទួលខុសត្រូវរដ្ឋប្បវេណី និងដើម្បីការពារជនរងគ្រោះដោយសារអំពើដែលអនីតិជនបានប្រព្រឹត្ត ច្បាប់កំណត់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជំនួសអនីតិជនដែលអ្នកទទួលខុសត្រូវនោះ ហៅថាអ្នកមានករណីយកិច្ចត្រួតពិនិត្យ ដែលនៅក្នុងករណីនេះ គឺអ្នកមានអំណាចមេបា។[27] ប៉ុន្តែបើកូនមានអាយុចាប់ពី ១៤ឆ្នាំឡើងទៅ ការទទួលខុសត្រូវរបស់អ្នកមានអំណាចមេបាត្រូវបន្ថយ មានន័យថា អនីតិជនត្រូវទទួលខុសត្រូវចំពោះការខូចខាតរបស់អ្នកដទៃផងដែរ ដោយសារអំពើរបស់ខ្លួន ពោលគឺជាការទទួលត្រូវដោយសាមគ្គីភាព រវាងអ្នកមានអំណាចមេបា និងកូន។[28]

---

[23]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦០ កថាខណ្ឌទី១។

[24]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦០ កថាខណ្ឌទី២ ។

[25]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៩។

[26]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧៤៥ កថាខណ្ឌទី១។

[27]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧៤៦ កថាខណ្ឌទី១។

[28]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧៤៦ កថាខណ្ឌទី២។

មួយវិញទៀត អ្នកមានអំណាចមេបា អាចរួចផុតអំពីការទទួលខុសត្រូវដោយសាមគ្គីចំពោះសំណងការខូចខាតបាន ប្រសិនបើអាចបញ្ជាក់បានថា ខ្លួនបានបំពេញករណីយកិច្ចជាប្រក្រតីដូចជា នៅពេលកូនប្រព្រឹត្តអំពើអនីត្យានុកូល កូនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់សាលារៀនជាអាទិ៍។[29] មួយវិញទៀតកូនអាចមានទ្រព្យសម្បត្តិតាមប្រទានកម្ម ឬសន្តតិកម្ម ហេតុនេះអាចទទួលខុសត្រូវដោយសាមគ្គីជាមួយអ្នកមានអំណាចមេបា ប៉ុន្តែនៅក្នុងករណីកូនគ្មានទ្រព្យសម្បត្តិ កូនមិនអាចទទួលខុសត្រូវជាមួយអ្នកមានអំណាចមេបាបានឡើយ ទោះបីជាមានអាយុច្រើនជាង ១៤ ឆ្នាំក៏ដោយ ហើយសម្រាប់ស្ថានភាពនេះ អ្នកមានអំណាចមេបានឹងទទួលខុសត្រូវចំពោះសំណងការខូចខាតទាំងស្រុង។

### ២.២.២.សិទ្ធិ និងករណីយកិច្ចទាក់ទងនឹងអ្នកគ្មានអំណាចមេបា

សិទ្ធិ និងករណីយកិច្ចរបស់ឪពុក ឬ ម្តាយដែលពុំមានអំណាចមេបា ក្នុងករណីដែល ឪពុកម្តាយនោះបានលែងលះគ្នា ឬដោយសារតែឪពុក ឬម្តាយដែលពុំមានអំណាចមេបា ជាធម្មតា តែងតែមិនស្នាក់នៅជាមួយកូន ឪពុក ឬម្តាយនោះត្រូវបានហៅថា ឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូន។

#### ២.២.២.១.ការចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន

ការប្រាស្រ័យទាក់ទងកូន ជាទំនាក់ទំនងតាមផ្លូវច្បាប់សម្រាប់បុគ្គលដែលគ្មានអំណាចមេបា ក្រោយការលែងលះ ដែលត្រូវបានធានាជាអប្បបរមា ក្នុងន័យមនោសញ្ចេតនា និងក្តីស្រលាញ់របស់ឪពុក ឬម្តាយដែលគ្មានអំណាចមេបាចំពោះកូន ក្នុងទម្រង់មួយដែលមានលក្ខណៈសមស្របតាមការព្រមព្រៀងរបស់ឪពុក និងម្តាយ ឬតាមសេចក្តីសម្រេចរបស់តុលាការ ប្រសិនបើគ្មានការព្រមព្រៀង។

ប្រសិនបើមានការលែងលះគ្នា ឪពុក ឬម្តាយដែលគ្មានអំណាចមេបាក្រោយការលែងលះ ត្រូវមានសិទ្ធិជួបប្រាស្រ័យទាក់ទងកូន ដោយបុគ្គលដែលគ្មានអំណាចមេបានោះត្រូវដាក់ពាក្យសុំមកតុលាការ ហើយប្រសិនបើគ្មានពាក្យសុំតុលាការមិនអាចសម្រេចអំពីករណីនេះបានឡើយ។ មួយវិញទៀត នៅពេលដាក់ពាក្យសុំមកតុលាការ បុគ្គលដែលមានប្រយោជន៍ក្នុងការកំណត់អំពីវិធីនៃការប្រាស្រ័យទាក់ទងកូន ក៏ដូចជាតុលាការត្រូវពិចារណាឱ្យបានស៊ីជម្រៅអំពីខ្លឹមសារនៃការប្រាស្រ័យទាក់ទងកូននេះ ដើម្បីឱ្យខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ អាចអនុវត្តដោយបង្ខំតាមច្បាប់បាន ប្រសិនបើភាគីដែលមានអ្នកមានអំណាចមេបាមិនសហការ នៅពេលរឿងក្តីនោះត្រូវបានបញ្ចប់ និងចូលជាស្ថាពរ។[30]

ឪពុក ឬម្តាយដែលមិនបានរស់នៅជាមួយកូន អាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។ វាគឺជាសិទ្ធិហើយជាមួយគ្នា ក៏ជាករណីយកិច្ចរបស់ឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូនដែរ។ ម៉្យាងវិញ

---

[29]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៧៤៦ កថាខណ្ឌទី៣។

[30]ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, លេខ នស/រកម/០៦១០/០០៨, ២០ ឧសភា ២០១០,មាត្រា២២ និង មាត្រា ២៣ (ចាប់ពីពេលនេះទៅហៅថា ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល)។

ទៀត កូនក៏មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូនដែរ។ ទោះបីជាឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូនមិនមែនជាអ្នកដែលមានអំណាចមេបាក៏ដោយ ដរាបណាគាត់នៅតែជាឪពុក ឬម្តាយ នោះឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូន ចាំបាច់ត្រូវចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន ដើម្បីការរលូតលាស់ដ៏ប្រសើររបស់កូន។

ផ្ទុយទៅវិញ ប្រសិនបើឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូនធ្លាប់បានរំលោភបំពានទៅលើកូនពីអតីតកាល ឬប្រសិនបើការចូលជួប ឬប្រាស្រ័យទាក់ទងគ្នា មិនបណ្តាលឱ្យមានផលប្រយោជន៍ដល់សុខុមាលភាពរបស់កូននោះទេ ឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូននោះអាចនឹងត្រូវហាមឃាត់មិនឱ្យទាក់ទងជាមួយនឹងកូន។ សុខុមាលភាពរបស់កូនមានអាទិភាពជាងបញ្ហាផ្សេងៗទាំងអស់។ ប្រសិនបើការចូលជួប ឬការប្រាស្រ័យទាក់ទងគ្នាជាមួយឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូន អាចជួយដល់ការរីកលូតលាស់របស់កូន ការចូលជួប ឬការប្រាស្រ័យទាក់ទងគ្នានេះគួរតែត្រូវបានអនុញ្ញាត រីឯប្រសិនបើធ្វើឱ្យមានការរាំងស្ទះ ឬអាចនឹងបណ្តាលឱ្យមានការរីកលូតលាស់របស់កូន ការចូលជួប ឬការប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានអនុញ្ញាតឡើយ។

ម្យ៉ាងវិញទៀត ការជួប និងការប្រាស្រ័យទាក់ទងគ្នានេះ មិនគួរត្រូវបានផ្សាភ្ជាប់ជាមួយនឹងការបែងចែកបន្ទុកនៃសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគ្មានការគិតគូឬគ់ចត់ឡើយ។ មានន័យថា ទោះបីជាឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូនពុំបានទទួលបន្ទុកនូវចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូនក៏ដោយ ក៏រឿងនោះមិនត្រូវយកមកធ្វើជាមូលហេតុក្នុងការហាមឃាត់ឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូននោះ មិនឲ្យចូលជួប ឬប្រាស្រ័យទាក់ទងជាមួយកូន ឬក្នុងការតម្រូវឱ្យឪពុក ឬម្តាយដែលមិនរស់នៅជាមួយកូននោះ បង់ប្រាក់ចំណែកសោហ៊ុយដើម្បីគ្រប់គ្រងថែរក្សាកូន ជាថ្នូរនឹងការយល់ព្រមឱ្យចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូននោះ។ ការចូលជួប និងការប្រាស្រ័យទាក់ទងនេះ មិនត្រូវយកមកប្រើជាមធ្យោបាយក្នុងការចរចារឡើយ។[31] ផ្អែកលើមូលដ្ឋានទាំងនេះ សេចក្តីសម្រេចបញ្ចប់ការប្រាស្រ័យទាក់ទងកូនអាចមានខ្លឹមសារបង្គាប់ឱ្យដើមចោទនាំកូនប្រុស ឈ្មោះ ក ដែលជាកូនរបស់ដើមចោទ និងចុងចម្លើយ មកឱ្យចុងចម្លើយ ដើម្បីជួបប្រាស្រ័យទាក់ទាក់ជាមួយចុងចម្លើយ តាមវិធីដូចខាងក្រោម៖

ក.ចំនួនដង៖ ក្នុងមួយសប្តាហ៍មួយដង នៅថ្ងៃអាទិត្យ។

ខ.រយៈពេលនៃការចូលជួប៖ មួយលើកប្រាំបីម៉ោង។ ម៉ោងជាក់លាក់អាចគូភាគីពិភាក្សា បើពិភាក្សាមិនបានអាចកំណត់គិតចាប់ពីម៉ោង ០៩ ដល់ម៉ោង ១៧។

[31] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រ១០៤០។

គ.វិធីប្រគល់៖ ដើមចោទប្រគល់កូនឱ្យចុងចម្លើយនៅទីកន្លែងប្រគល់ ហើយនៅពេលបញ្ចប់រយៈពេលចូលជួប ចុងចម្លើយប្រគល់កូនឱ្យដើមចោទនៅទីកន្លែងប្រគល់។ ទីកន្លែងប្រគល់អាស្រ័យលើការពិភាក្សា បើមិនអាច ពិភាក្សាទេពិចារណាអំពីប្រយោជន៍កូន គប្បីយកទីតាំងដែលនៅជិតកន្លែងកូនស្នាក់នៅ។

ឃ.ថ្ងៃជំនួស៖ ក្នុងករណីមិនអាចអនុវត្តតាមការកំណត់ខាងលើនេះទេ ដូចជា កូនឈឺ ឬជាប់កម្មវិធីរបស់សាលា ឬឪពុកឈឺ ឬម្ដាយឈឺជាអាទិ៍ គូភាគីត្រូវកំណត់ថ្ងៃផ្សេងតាមការពិភាក្សា បើមិនអាចពិភាក្សាគ្នាត្រូវយកថ្ងៃសុក្រ នៃសប្ដាហ៍នីមួយៗ។

### ២.២.២.២.ការទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

ការរាយការណ៍អំពីស្ថានភាពកូន ជាទំនាក់ទំនងតាមផ្លូវច្បាប់សម្រាប់បុគ្គលដែលគ្មានអំណាចមេបា ក្រោយការលែងលះដែលត្រូវបានធានាជាអប្បបរមា ក្នុងន័យមនោសញ្ចេតនា និងក្ដីស្រឡាញ់របស់ឪពុក ឬម្ដាយ ដែលគ្មានអំណាចមេបាចំពោះកូន ក្នុងទម្រង់មួយដែលមានលក្ខណៈសមស្របតាមការព្រមព្រៀងរបស់ ឪពុក និងម្ដាយ ឬតាមសេចក្ដីសម្រេចរបស់តុលាការ បើគ្មានការព្រមព្រៀង។

ប្រសិនបើមានការលែងលះគ្នា ឪពុក ឬម្ដាយដែលគ្មានអំណាចមេបា ត្រូវមានសិទ្ធិទទួលដំណឹងអំពី ស្ថានភាពកូន ដោយឪពុក ឬម្ដាយនោះ ត្រូវដាក់ពាក្យសុំមកតុលាការ ហើយប្រសិនបើគ្មានពាក្យសុំតុលាការ មិនអាចសម្រេចអំពីករណីនេះបានឡើយ។ មួយវិញទៀត នៅពេលដាក់ពាក្យសុំមកតុលាការ បុគ្គលដែលមាន ប្រយោជន៍ក្នុងការកំណត់អំពីវិធីនៃការរាយការណ៍អំពីស្ថានភាពកូនក៏ដូចជាតុលាការ ត្រូវពិចារណាឱ្យបានស៊ី ជម្រៅអំពីខ្លឹមសារនៃវិធីរាយការណ៍អំពីស្ថានភាពកូន ដើម្បីឱ្យខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់ អាចអនុវត្តដោយ បង្ខំតាមច្បាប់បាន ប្រសិនបើភាគីម្ខាងទៀត(អ្នកមានអំណាចមេបា)មិនសហការ នៅពេលរឿងក្ដីនោះត្រូវបាន បញ្ចប់ និងចូលជាស្ថាពរ។

ឪពុក ឬម្ដាយដែលពុំមានអំណាចមេបាក៏នៅតែជាឪពុក ឬម្ដាយតាមច្បាប់របស់កូនដែរ។ ម្យ៉ាងទៀត ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូនអាចមានករណីយកិច្ចជាច្រើន ក្នុងនាមជាឪពុក ឬម្ដាយ ដូចជា ករណីយកិច្ចក្នុងការបង់ការចំណាយលើការចិញ្ចឹមកូនជាដើម។ ដូច្នេះ ការដឹងពីស្ថានភាពកូនដែលមិនរស់នៅ ជាមួយខ្លួន គឺជាសិទ្ធិរបស់ឪពុក ឬម្ដាយដែលមិនរស់នៅជាមួយកូន ព្រមជាមួយគ្នានេះគឺជាករណីយកិច្ចរបស់ ឪពុក ឬម្ដាយនោះ ដើម្បីធានាឲ្យមានការរីកលូតលាស់បានយ៉ាងល្អរបស់កូន។[32]

### ២.២.២.៣.ការពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងនឹងកូន

នៅក្នុងសំណុំរឿងលែងលះ ក្រៅពីការបែងចែកទ្រព្យរួមរបស់ប្ដីប្រពន្ធ ប្រសិនបើប្ដីប្រពន្ធដែលជាគូភាគី វិវាទនោះមានកូនជាអនីតិជន (កូនមានអាយុក្រោម១៨ ឆ្នាំ) ហើយតុលាការបានកំណត់អ្នកមានអំណាចមេបា គឺជាម្ដាយជាអាទិ៍ ឪពុកដែលគ្មានអំណាចមេបា ក្រោយការលែងលះមានសិទ្ធិជួបប្រាស្រ័យទាក់ទងកូនជា

[32]សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រា១០៥០។

អនីតិជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ម្តាយ និងសិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូនតាមរយៈឪពុកនោះស្នើសុំទៅតុលាការ។ ក្រៅពីករណីខាងលើនេះ ឪពុកដែលគ្មានអំណាចមេបា ច្បាប់ផ្តល់សិទ្ធិបន្ថែមទៀតទាក់ទងនឹងកូន។[33] ដើម្បីលើកកម្ពស់សុខុមាលភាពរបស់កូន និងដើម្បីឱ្យមានប្រសិទ្ធភាពនូវសិទ្ធិ និងករណីយកិច្ចរបស់ឪពុក ឬម្តាយដែលពុំមានអំណាចមេបា ជាគោលការណ៍អ្នកដែលមានអំណាចមេបា និង ឪពុក ឬម្តាយដែលពុំមានអំណាចមេបាត្រូវតែពិភាក្សាគ្នាអំពីចំណុចដែលបានកំណត់ដូចជា៖

– ការអប់រំកូន៖ ជាស្ថានភាពពាក់ព័ន្ធនឹងការសិក្សារបស់កូនជាអនីតិជន ថាតើរៀននៅសាលាណា រៀននៅក្នុងស្រុក ឬបរទេសជាអាទិ៍។ ដោយសារតែពាក់ព័ន្ធនឹងការចំណាយដ៏ច្រើននោះ ករណីនេះនឹងមានការប៉ះពាល់ដល់ការបែងចែកការផ្ទុកនៃសោហ៊ុយសម្រាប់ការចិញ្ចឹមកូន។ ម្យ៉ាងទៀត ការអប់រំគឺជាកត្តាសំខាន់សម្រាប់ជីវិត និងអនាគតរបស់កូន។

– ការផ្លាស់ប្តូរលំនៅឋានរបស់កូន៖ ជាស្ថានភាពពាក់ព័ន្ធនឹងបរិយាកាសនៃការរស់នៅ ហើយផ្សាភ្ជាប់ដល់សិទ្ធិជួបប្រាស្រ័យទាក់ទងកូន សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពកូន ប្រសិនបើលំនៅឋានរបស់កូនត្រូវបានផ្លាស់ប្តូរពីរាជធានីទៅខេត្ត ឬពីខេត្តមករាជធានីជាអាទិ៍។ នេះជាចំណុចមិនល្អ សម្រាប់កូន និងឪពុកម្តាយដែលរស់នៅបែកបាក់គ្នាទេ។

– ការអនុញ្ញាតឱ្យកូនបំពេញការងារ ឬធ្វើអាជីវកម្ម៖ ជាធម្មតា កូនជាអនីតិជនមិនអាចប្រកបការងារ ឬធ្វើអាជីវកម្មខណៈពេលកំពុងទទួលការអប់រំនៅសាលា ស្របពេលជាមួយគ្នានោះទេ និងជាទូទៅ បើកូនជាអនីតិជនរៀនបណ្តើរធ្វើការបណ្តើរ គឺនឹងប៉ះពាល់ដល់ការសិក្សាកូន អាជីវកម្មខ្លះមិនសមស្របជាមួយកូនជាអនីតិជននោះទេ។

– ការព្យាបាលកូនដែលពាក់ព័ន្ធនឹងអាយុជីវិត៖ ការព្យាបាលដែលពាក់ព័ន្ធនឹងអាយុជីវិតរបស់កូន ជាអនីតិជន ដូចជាកូនមានជំងឺមហារីកតម្រូវឱ្យមានការវះកាត់ ឬព្យាបាលដោយប្រើថ្នាំ ឬបញ្ឈប់ការព្យាបាល ឬផ្លាស់ប្តូរវិធីព្យាបាល ឬពេទ្យ ឬអំឡុងពេលនៃការព្យាបាល ជាអាទិ៍ ម្តាយជាអ្នកមានអំណាចមេបា ត្រូវពិភាក្សាជាមួយឪពុករបស់កូននោះ ពីព្រោះចំណុចនេះសំខាន់ពាក់ព័ន្ធអនាគតកូន និងការចំណាយដែលត្រូវទទួលខុសត្រូវរួមគ្នាក្នុងនាមជាឪពុកម្តាយរបស់កូន។

– ការចាត់ចែងទ្រព្យសម្បត្តិរបស់កូន៖ ក្នុងករណីកូនជាអនីតិជនមានទ្រព្យផ្ទាល់ខ្លួន ដូចជា មានកម្មសិទ្ធិនៅលើផ្ទះណាមួយ ដែលទទួលបានប្រទានកម្មពីជីដូន ជាអាទិ៍ ហើយម្តាយដែលជាអ្នកមានអំណាចមេបាចង់លក់ផ្ទះនេះ ត្រូវពិភាក្សាជាមួយឪពុករបស់កូនជាមុនសិន។

[33] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ១០៤២។

– ការគ្រប់គ្រងថែរក្សាកូន៖ ចំណុចនេះជាស្ថានភាពពាក់ព័ន្ធនឹងផ្លូវចិត្ត និងសុខមាលភាពរបស់កូនជាអនីតិជន ផ្តោតលើករណីឱ្យកូនជាអនីតិជនរៀបអាពាហ៍ពិពាហ៍ ឬបង្កើតរបបស្នុំកូនជាមួយប្តីក្រោយជាអាទិ៍ ត្រូវចាត់ទុកថាជាចំណុចចាំបាច់ដែលត្រូវពិភាក្សាជាមុនជាមួយឪពុកកូននោះ។

– ការគ្រប់គ្រងទ្រព្យសម្បត្តិកូន៖ ក្នុងករណីកូនជាអនីតិជនមានទ្រព្យផ្ទាល់ខ្លួន ដូចជា មានកម្មសិទ្ធិនៅលើផ្ទះណាមួយដែលទទួលបានប្រទានកម្មពីជីដូន ជាអាទិ៍ ហើយម្តាយដែលជាអ្នកមានអំណាចមេបាចង់ជួសជុលផ្ទះ ឬមានអ្នកដទៃបំពានលើផ្ទះនេះ ដោយតម្រូវធ្វើបណ្តឹងទាមទារឱ្យប្រគល់ផ្ទះនេះ ជាអាទិ៍ មុនពេលធ្វើម្តាយត្រូវពិភាក្សាជាមួយឪពុករបស់កូនជាមុនសិន។

ទោះបីជាឪពុកម្តាយបានលែងលះគ្នាក៏ដោយ និងទោះបីតុលាការបានកំណត់ថាម្តាយជាអ្នកមានអំណាចមេបាចំពោះកូនជាអនីតិជនក៏ដោយ ដើម្បីសុខុមាលភាពរបស់កូន និងផ្លូវចិត្តរបស់កូន ជាពិសេសធានានូវផលប្រយោជន៍របស់កូន ឪពុកដែលគ្មានអំណាចមេបា និងម្តាយដែលមានអំណាចមេបា នៅតែត្រូវសហការនិងពិភាក្សាគ្នាជាចាំបាច់អំពីចំណុចខាងលើនេះ លើកលែងតែមានភាពចាំបាច់បន្ទាន់ផ្អែកតាមករណីជាក់ស្តែងនិងប្រកបដោយសុចរិតភាពទើបមិនចាំបាច់ពិភាក្សា។ មួយវិញទៀត អាចមានករណីលើកឡើងថា បើពិភាក្សាបរាជ័យគឺម្តាយដែលជាអ្នកមានអំណាចមេបា។ ប៉ុន្តែមុនសម្រេចត្រូវពិភាក្សា ទោះបីម្តាយដែលជាអ្នកមានអំណាចមេបាមានសិទ្ធិសម្រេចចុងក្រោយក៏ដោយ បើការសម្រេចនោះមិនសមស្របនឹងផលប្រយោជន៍របស់កូន ម្តាយដែលមានអំណាចមេបានោះ អាចនឹងប្រឈមការផ្លាស់ប្តូរអំណាចមេបាបើមានការស្នើសុំរបស់ញាតិនៅក្នុង ៤ ថ្នាក់របស់កូនជាអនីតិជននោះទៅតុលាការបើមានមូលដ្ឋានគ្រប់គ្រាន់ និងភស្តុតាងបញ្ជាក់ថាការសម្រេចនោះបានប៉ះពាល់ផលប្រយោជន៍កូន ជាអាទិ៍។

## ២.៣. ការផ្លាស់ប្តូរអំណាចមេបា

ទោះបីជា អំណាចមេបាត្រូវបានកំណត់ក៏ដោយ តុលាការអាចផ្លាស់ប្តូរអ្នកមាអំណាចមេបាបាន តាមការទាមទាររបស់ញាតិក្នុង ៤ ថ្នាក់របស់កូន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍កូន។[34] ការផ្លាស់ប្តូរអ្នកមានអំណាចមេបា ជាយន្តការតាមផ្លូវតុលាការមួយដើម្បីសង្គ្រោះកូន ក្នុងករណីដែលអ្នកមានអំណាចមិនអាចអនុវត្តអំណាចមេបាបាន កាលបើមានមូលហេតុដូចខាងក្រោម៖

### ២.៣.១. ការព្យួរ ឬការដកហូតអំណាចមេបា

ការព្យួរ ឬការដកហូតអំណាចមេបាគឺជាយន្តការមួយដែលតាមរយៈនោះ តុលាការអាចព្យួរ ឬដកហូតអំណាចមេបាទាំងស្រុងពីអ្នកមានអំណាចមេបា ដោយសេចក្តីសម្រេចរបស់ខ្លួនតាមពាក្យសុំរបស់បុគ្គលដែលមានសិទ្ធិដាក់ពាក្យសុំក្នុងករណីដែលអ្នកមានអំណាចមេបាបានបំពានសិទ្ធិអំណាចមេបា ឬធ្វេសប្រហែសក្នុង

[34]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៩។

ការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា ដូចជា ការប្រើអំពើហិង្សាលើកូនដែលបណ្តាលឱ្យវងគ្រោះថ្នាក់ធ្ងន់ធ្ងរជាអាទិ៍។[35] ប៉ុន្តែប្រសិនបើ មូលហេតុនៃការព្យួរ ឬដកហូតនោះបានបញ្ចប់ តុលាការអាចប្រកាសការលុបចោលការព្យួរ ឬការដកហូតអំណាចមេបានោះបានតាមការទាមទាររបស់សាមីជនដែលទទួលការប្រកាសព្យួរ ឬដកហូតអំណាចមេបា ឬញាតិក្នុង៤ថ្នាក់របស់ជននោះ។[36] ឧទាហរណ៍ បើអ្នកមានអំណាចមេបាបានប្រព្រឹត្តអំពើហិង្សាលើកូន ដោយសារគ្រឿងញៀន ឬគ្រឿងស្រវឹង ហើយត្រូវបានព្យួរ ឬដកហូតអំណាចមេបា ប៉ុន្តែក្រោយមកបានផ្តាច់នូវការញៀន ឈប់ប្រើអំពើហិង្សា និងមានការសោកស្តាយនូវអ្វីដែលខ្លួនបានប្រព្រឹត្ត ហេតុនេះបុគ្គលនោះអាចទទួលបាននូវអំណាចមេបាវិញដោយការដាក់ពាក្យសុំទៅតុលាការឱ្យតុលាការឱ្យលុបចោលការព្យួរ ឬការដកហូតអំណាចមេបា។ ម៉្យាងវិញទៀត ក្រៅពីមូលហេតុខាងលើ អ្នកមានអំណាចមេបា អាចត្រូវបានប្រកាសព្យួរ ឬដកហូតអំណាចមេបាផងដែរ ក្នុងករណីដែលបានធ្វើឱ្យអន្តរាយទ្រព្យសម្បត្តិរបស់កូន ដោយសារការគ្រប់គ្រងមិនត្រឹមត្រូវដូចជា ការប្រើប្រាស់ ឬការយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួននៅទ្រព្យសម្បត្តិរបស់កូនជាអាទិ៍។[37] ប៉ុន្តែ បើមូលហេតុនៃការប្រកាសព្យួរ ឬដកហូតអំណាចមេបាបានបញ្ចប់ តុលាការអាចប្រកាសលុបចោលការព្យួរ ឬដកហូតអំណាចមេបាបានតាមការស្នើសុំរបស់សាមីជនដែលត្រូវបានប្រកាសព្យួរ ឬដកហូតអំណាចមេបា ឬញាតិក្នុង៤ថ្នាក់របស់ជននោះ។[38]

### ២.៣.២.ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា

ការលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា គឺជាយន្តការមួយដែលតាមរយៈនោះ តុលាការអនុញ្ញាតឱ្យអ្នកមានអំណាចមេបាទោល លាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ឬអំណាចនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនបាន កាលបើមានមូលហេតុមិនអាចជៀសវាងបាន ដូចជា អ្នកមានអំណាចមេបា ជាប់ពន្ធនាគារ ឬសម្រាកនៅមន្ទីរពេទ្យរយៈពេលវែង ជាអាទិ៍ តាមពាក្យសុំរបស់អ្នកមានអំណាចមេបា ប៉ុន្តែបើមូលហេតុនៃការលាឈប់អំណាចមេបានោះបានបញ្ចប់ អ្នកមានអំណាចមេបាដែលបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបាអាចទទួលបដិទាននូវអំណាចមេបានោះវិញ ដោយទទួលការអនុញ្ញាតពីតុលាការ។[39]

ជាធម្មតាឪពុក ឬម្តាយ ប្រើប្រាស់អំណាចមេបាដោយសហការគ្នា ក្នុងករណីបើឪពុក ឬម្តាយណាម្ខាងពុំអាចប្រើប្រាស់អំណាចមេបាបានទេ ដូចជា ករណីឪពុក ឬម្តាយបាត់បង់សតិជាអាទិ៍ ឪពុក ឬម្តាយម្ខាងទៀត

[35] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤៨។

[36] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤៩។

[37] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦១។

[38] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦២។

[39] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥០ និង មាត្រា១០៦៣។

ត្រូវប្រើប្រាស់អំណាចមេបានោះ។[40] ប៉ុន្តែករណីមានឪពុក ឬម្ដាយដែលជាអ្នកមានអំណាចមេបា ហើយកូនបានធ្លាក់ក្នុងស្ថានភាពកូន ដែលពុំមានអំណាចមេបា ដោយសារការប្រកាសព្យួរ ឬដកហូតអំណាចមេបា ឬលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា តុលាការអាចយកឪពុក ឬម្ដាយដែលពុំមានអំណាចមេបាមកធ្វើជាអ្នកមានអំណាចមេបារបស់កូនបាន។[41] ជាក់ស្ដែងករណី មេសា ជាអនីតិជនបានសម្រាលកូនដោយមិនទាន់បានរៀបអាពាហ៍ពិពាហ៍ ហេតុនេះ មេសា គឺជាអ្នកមានអំណាចមេបាលើកូនទោះបីជាលោក នី ជាឪពុកបានទទួលស្គាល់កូនក៏ដោយ ប៉ុន្តែមេសា ត្រូវបានលាឈប់ពីការធ្វើជាអ្នកមានអំណាចមេបា ករណីនេះតុលាការអាចយកលោក នី ដែលជាឪពុកមកធ្វើជាអ្នកមានអំណាចមេបាបាន។ ចំពោះករណីលែងលះ ប្រសិនបើកំណត់យកឪពុក ឬម្ដាយជាអ្នកមានអំណាចមេបាតាមការពិភាក្សាគ្នា ហើយអ្នកដែលមានអំណាចទោលនោះបានទទួលមរណភាព ឪពុក ឬម្ដាយដែលនៅរស់នឹងក្លាយជាអ្នកមានអំណាចមេបាដោយស្វ័យប្រវត្តិ។[42] ក្រៅពីករណីមរណភាព តុលាការអាចធ្វើការផ្លាស់ប្ដូរអ្នកមានអំណាចមេបាតាមការទាមទាររបស់អ្នកមានសិទ្ធិស្នើសុំ កាលបើអ្នកមានអំណាចមេបា ដែលត្រូវកំណត់នោះធ្វើឱ្យខូចប្រយោជន៍របស់កូន ដូចជាបានប្រព្រឹត្តអំពើណាមួយដែលមិនសមជាអ្នកមានអំណាចមេបា។

ផ្ទុយទៅវិញ បើពុំអាចផ្លាស់ប្ដូរអ្នកមានអំណាចមេបាទេ ដូចជាក្នុងករណីលែងលះ បានកំណត់យកម្ដាយជាអ្នកមានអំណាចមេបា ក្រោយមកម្ដាយបានទទួលមរណភាព ហេតុនេះឪពុកត្រូវក្លាយជាអ្នកមានអំណាចមេបា ប៉ុន្តែឪពុកបានលាឈប់ធ្វើជាអ្នកមានអំណាចមេបា ដោយសារខ្លួនរៀបការថ្មីដែលបណ្ដាលឱ្យកូនធ្លាក់ក្នុងស្ថានភាពពុំមានអ្នកអនុវត្តមេបា។ ដើម្បីសង្គ្រោះក្នុងករណីនេះ អាណាព្យាបាលសម្រាប់អនីតិជនចំពោះកូននោះត្រូវចាប់ផ្ដើម ដើម្បីបីបាច់ថែរក្សានិងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អនីតិជននោះ។[43] ទោះបីជាយ៉ាងណាក៏ដោយមានករណីខ្លះអ្នកមានអំណាចមេបាអាចបីបាច់ថែរក្សារូបកាយកូន ពោលគឺអាចបំពេញករណីយកិច្ចទាក់ទងនឹងកូនបានល្អដោយពុំមានបញ្ហាអ្វីនោះទេ ប៉ុន្តែអ្នកមានអំណាចមេបានោះមិនអាចគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូនឡើយដោយសារការប្រកាសព្យួរ ឬដកហូតអំណាចមេបា ឬលាឈប់ ក្នុងករណីនេះ របបអាណាព្យាបាលសម្រាប់អនីតិជនមិនត្រូវបានចាប់ផ្ដើមនោះទេ ពោលគឺតុលាការត្រូវជ្រើសតាំងអ្នកតំណាងពិសេសឱ្យកូនដោយឆន្ទានុសិទ្ធិ។[44]

[40] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៣៦ វាក្យខណ្ឌទី២។

[41] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥១ កថាខណ្ឌទី១។

[42] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥១ កថាខណ្ឌទី៣។

[43] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥២។

[44] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦៥។

## ២.៤. ការបញ្ចប់អំណាចមេបា

អំណាចមេបាត្រូវបញ្ចប់នៅពេលដែលកូនមាននីតិភាព មានន័យថា នៅពេលដែលកូនមានអាយុគ្រប់តាមការកំណត់របស់ច្បាប់ កូននឹងរួចផុតពីអំណាចមេបា។ ទោះបីជាកូនមិនទាន់គ្រប់អាយុតាមការកំណត់របស់ច្បាប់ក៏ដោយ ប៉ុន្តែកូនអាចរួចផុតពីអំណាចមេបាបាន ក្នុងករណីដែលកូនបានទទួលអត្តាធីនភាពពីព្រោះអនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថាបានដល់នីតិភាព។[45]

នៅពេលដែលអំណាចមេបាបានបញ្ចប់ ជាលទ្ធផលការគ្រប់គ្រងទំនាក់ទំនងកូន និងការគ្រប់គ្រងទ្រព្យសម្បត្តិក៏ត្រូវបានបញ្ចប់ដែរ។ ហើយទាក់ទងនឹងការបញ្ចប់ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន អ្នកមានអំណាចមេបាត្រូវគណនាចំណូលចំណាយក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ដោយគ្មានការយឺតយ៉ាវ។[46] នៅក្នុងអំឡុងពេលនៃការអនុវត្តអំណាចមេបាអ្នកមានអំណាចមេបា បានចំណាយសោហ៊ុយជាច្រើនទាក់ទងនឹងការចិញ្ចឹមកូន រួមទាំងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន ប៉ុន្តែការចិញ្ចឹមកូន គឺជាករណីយកិច្ចរបស់អ្នកមានអំណាចមេបា ហេតុនេះ ពុំសមរម្យឡើយក្នុងការឱ្យកូនបង់សងមកវិញ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ច្បាប់បានកំណត់ថា បើអ្នកមានអំណាចមេបាបានទទួលចំណូលពីទ្រព្យសម្បត្តិរបស់កូន ត្រូវចាត់ទុកថាជាការទូទាត់និងសោហ៊ុយចិញ្ចឹមបីបាច់កូន និងសោហ៊ុយគ្រប់គ្រងទ្រព្យសម្បត្តិរបស់កូន។[47] មានន័យថា នៅក្នុងអំឡុងពេលអនុវត្តសិទ្ធិអំណាចមេបា អ្នកមានអំណាចមេបាអាចអាស្រ័យផលពីទ្រព្យសម្បត្តិរបស់កូនបាន គឺផលដែលទទួលបានពីទ្រព្យសម្បត្តិនោះ ដូចជាថ្លៃឈ្នួល ជាអាទិ៍ អ្នកមានអំណាចមេបាមិនចាំបាច់ប្រគល់ឱ្យកូននៅពេលដែលកូនមាននីតិភាពទេ។ផ្ទុយមកវិញ ចំពោះទ្រព្យសម្បត្តិដែលបានផ្តល់ដោយមិនគិតថ្លៃឱ្យកូន ហើយអ្នកផ្តល់ឱ្យនោះបានបង្ហាញឆន្ទៈមិនឱ្យអ្នកមានអំណាចមេបាអាស្រ័យផលពីទ្រព្យសម្បត្តិនោះ អ្នកមានអំណាចមេបាមិនអាចអាស្រ័យផលពីទ្រព្យសម្បត្តិនោះបានឡើយ មានន័យថា ចំណូលដែលទទួលបានពីទ្រព្យសម្បត្តិរបស់កូន ត្រូវប្រគល់ឱ្យកូននៅពេលដែលកូនដល់នីតិភាព ពោលគឺមិនអាចធ្វើការទូទាត់ដូចកំណត់ខាងលើនោះទេ។[48] ម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកមានអំណាចមេបាបានចាត់ចែងលក់ទ្រព្យសម្បត្តិរបស់កូនជាអាទិ៍ នៅពេលដែលកូនមាននីតិភាព ប្រាក់ដែលបានមកពីការលក់នេះត្រូវប្រគល់ឱ្យកូន ប៉ុន្តែប្រសិនបើអ្នកមានអំណាចមេបាមិនបានប្រគល់ប្រាក់ដែលបានមកពីការលក់ទ្រព្យសម្បត្តិរបស់កូនទេ កូនមានសិទ្ធិទាមទារឱ្យអ្នកមានអំណាចមេបាប្រគល់ ដែលអំឡុងពេលនៃការទាមទារនោះគឺ បីឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិអំណាចនៃ

[45]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា២១ និងមាត្រា២២។

[46]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៦ វាក្យខណ្ឌទី១។

[47]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៦ វាក្យខណ្ឌទី២។

[48]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៧។

ការអនុវត្តការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់។[49] សិទ្ធិអំណាចមេបា ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិបានរលត់ក្នុងពេលដែលកូនពុំទាន់ក្លាយជានីតិជន បើកូនពុំទាន់មានអ្នកតំណាងដែលច្បាប់បានកំណត់ អំឡុងពេលនៃការទាមទារគឺបីឆ្នាំ គិតចាប់ពីពេលដែលកូននោះក្លាយជានីតិជន ឬពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់បានកាន់តំណែង។[50]

ទោះបីជាអំណាចមេបាបានបញ្ចប់ដោយសារតែកូនបានដល់នីតិភាព ឬសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិត្រូវបានព្យួរ ឬដកហូត មានន័យថា អ្នកមានអំណាចមេបា នៅតែបន្តគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូនដដែលរហូតដល់កូន ឬអ្នកគ្រប់គ្រងថ្មីមានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងទ្រព្យសម្បត្តិនោះ ព្រោះទ្រព្យសម្បត្តិនឹងស្ថិតនៅក្នុងហានិភ័យ បើអ្នកមានអំណាចមេបាលែងគ្រប់គ្រងទ្រព្យសម្បត្តិភ្លាមមុនដែលកូន ឬអ្នកគ្រប់គ្រងថ្មីមិនទាន់មានលទ្ធភាពចាប់ផ្តើមគ្រប់គ្រងទ្រព្យសម្បត្តិ។[51]

[49]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦០ កថាខណ្ឌទី១។

[50]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៦០ កថាខណ្ឌទី២។

[51]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៥៩។

# ជំពូកទី៣
# ការបែងចែកទ្រព្យសម្បត្តិ និង
# សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

# ជំពូកទី៣

# ការបែងចែកទ្រព្យសម្បត្តិនិងសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

## ៣.១. ការបែងចែកទ្រព្យសម្បត្តិ

នៅក្នុងទំនាក់ទំនងប្តីប្រពន្ធ ការគ្រប់គ្រង ចាត់ចែង និងបែងចែកទ្រព្យសម្បត្តិអាចនាំទៅរកវិវាទ ទាំងនៅក្នុង ពេលជាប់ចំណងអាពាហ៍ពិពាហ៍ ក៏ដូចជា នៅពេលលែងលះ។ ដើម្បីបង្ការ និងដោះស្រាយវិវាទទាំងនេះ ក្រមរដ្ឋប្បវេណីខ្មែរ មានចែងអំពីប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិប្តីប្រពន្ធ។ បើប្តីប្រពន្ធបានធ្វើកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធមុនពេលមានចំណងអាពិពាហ៍ពិពាហ៍ ឬ ក្រោយពេលអាពាហ៍ពិពាហ៍ នោះការបែងចែកទ្រព្យសម្បត្តិនៅពេលលែងលះត្រូវគោរពតាមកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ បើប្តីប្រពន្ធមិនបានធ្វើកិច្ចសន្យាចំពោះទ្រព្យសម្បត្តិនោះទេ ការបែងចែក គ្រប់គ្រង និងចាត់ចែងទ្រព្យ គឺត្រូវធ្វើតាមច្បាប់ដែលបានកំណត់ដែលគេហៅថាប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់។ ទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ មានពីរគឺ ៖

ទ្រព្យសម្បត្តិរួម គឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែង តែទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬតម្លៃតបពីការចាត់ចែង ទ្រព្យសម្បត្តិដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ឬទ្រព្យសម្បត្តិដែល ទទួលបានដោយប្រទានកម្ម សន្តតិកម្ម អាពាហ៍ពិពាហ៍។[52]

ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់៖

ក. ទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍

ខ. ទ្រព្យសម្បត្តិ ដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍

គ. ទ្រព្យសម្បត្តិជាតម្លៃតប ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិ ដែលបានកំណត់នៅក្នុងចំណុច ក និងចំណុច ខ ខាងលើនេះ។

### ៣.១.១.ការបែងចែកទ្រព្យសម្បត្តិតាមកិច្ចសន្យា

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិអំពីប្រព័ន្ធទ្រព្យសម្បត្តិតាមកិច្ចសន្យាបានទទួលស្គាល់នូវកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ។ ពោលគឺ ប្តីប្រពន្ធអាចធ្វើកិច្ចសន្យាអំពីទំនាក់ទំនងទ្រព្យសម្បត្តិនៅ

[52]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧៣។

មុន ឬក្រោយពេលអាពាហ៍ពិពាហ៍បាន។ ប៉ុន្តែកិច្ចសន្យានេះមិនអាចធ្វើផ្ទុយនឹងបញ្ញត្តិស្តីពីសិទ្ធិទាមទារអាហារកាតព្វកិច្ចនិងភាគបម្រុងបានឡើយ។

កិច្ចសន្យាទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធត្រូវបានធ្វើឡើង ដើម្បីទប់ស្កាត់វិវាទលើទំនាក់ទំនងទ្រព្យសម្បត្តិ និងដើម្បីបញ្ជាក់ឱ្យច្បាស់អំពីទំនាក់ទំនងសិទ្ធិ និងករណីយកិច្ចរបស់ប្តីប្រពន្ធ។ ទំនាក់ទំនងជាក់ស្តែងរវាងប្តីប្រពន្ធមានលក្ខណៈច្រើនបែបច្រើនយ៉ាង ហើយបញ្ញត្តិនេះផ្តល់លទ្ធភាពឱ្យប្តីប្រពន្ធនូវជម្រើសដែលមានលក្ខណៈបត់បែនសមស្របទៅតាមភាពចាំបាច់របស់ប្តីប្រពន្ធជាក់លាក់។ កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធនេះ ក៏មានអានុភាពសម្របសម្រួលការពិភាក្សាអំពីអនាគតរបស់ប្តីប្រពន្ធផងដែរ។[53] កិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ជាកិច្ចសន្យាមួយដែលជួយសម្រួល និងបង្កើននូវភាពជាក់លាក់ដល់ប្តីប្រពន្ធដែលបានចុះកិច្ចសន្យានោះ ទាក់ទងទៅនឹងបញ្ហាសំខាន់ៗជាច្រើន រួមមានការចាត់ចែងនូវសិទ្ធិលើទ្រព្យសម្បត្តិ កាតព្វកិច្ច និងករណីយកិច្ចដែលតម្រូវឱ្យសហព័ទ្ធគោរព និងអនុវត្តតាមគោលការណ៍ដែលច្បាប់បានកំណត់។ កិច្ចសន្យានេះមានទម្រង់ជាលិខិតលាយលក្ខណ៍អក្សរ ហើយចុះបញ្ជីកិច្ចសន្យាទ្រព្យសម្បត្តិប្តីប្រពន្ធ ក្នុងគោលបំណងកំណត់ការបែងចែករវាងទ្រព្យរួម និងទ្រព្យដោយឡែក គឺនាំឱ្យមានភាពងាយស្រួលចំពោះសហព័ទ្ធនៅក្នុងការប្រើប្រាស់សិទ្ធិលើទ្រព្យដែលខ្លួនមាន លើសពីនេះទៅទៀតនៅពេលដែលសហព័ទ្ធឈានដល់ការបញ្ចប់ចំណងអាពាហ៍ពិពាហ៍ ហើយមានជម្លោះដែលទាក់ទងទៅនឹងបញ្ហាទ្រព្យ នោះកិច្ចសន្យាដែលទាក់ទងនឹងការចុះបញ្ជីទ្រព្យសម្បត្តិប្តីប្រពន្ធនឹងក្លាយជាកម្មវត្ថុដ៏សំខាន់នៅក្នុងការបែងចែកទ្រព្យ។ ការកំណត់នូវទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធតាមកិច្ចសន្យា ជាកត្តាមួយដែលជួយឱ្យសហព័ទ្ធមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ និងមានសមភាពក្រោយពេលចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់។

### ៣.១.២. ការបែងចែកទ្រព្យសម្បត្តិតាមច្បាប់

នៅពេលដែលមានពាក្យបណ្តឹងលែងលះ ឬពាក្យសុំលែងលះ ត្រូវបានដាក់ទៅតុលាការប្តី ឬប្រពន្ធអាចទាមទារឱ្យតុលាការបែងចែកទ្រព្យសម្បត្តិបាន ប្រសិនបើប្តីប្រពន្ធពុំអាចពិភាក្សាបែងចែកទ្រព្យតាមការព្រមព្រៀងបានទេ សហព័ទ្ធនីមួយៗត្រូវទទួលនូវទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន។[54] បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗមានសិទ្ធិទទួលយក ១ភាគ២ នៃទ្រព្យរួម មានន័យថា ដើម្បីធ្វើឱ្យមានភាពស្មើគ្នានៃអាពាហ៍ពិពាហ៍ បញ្ញត្តិច្បាប់បានយកចំណែក១ភាគ២ជាគោលការណ៍ បើមានករណីពិសេស និងមានការទាមទាររបស់ប្តីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្តនិងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគី

[53]សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, មាត្រា៩៦៩។

[54]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៧២។

នីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។ ច្បាប់បានផ្តល់លទ្ធភាពឱ្យបែងចែកចំណែក១ភាគ៣ ឬ ១ភាគ៤ ក៏បាន។[55] ហើយការវាយតម្លៃការងារគេហកិច្ចបានបង្ហាញយ៉ាងច្បាស់ថា ត្រូវពិចារណានិងចាត់ទុកថា ការងារគេហកិច្ចរបស់មេផ្ទះក៏ដោយ ក៏ត្រូវវាយតម្លៃថាជាការបរិច្ចាគសម្រាប់ធ្វើលទ្ធកម្មថែរក្សា និងបង្កើនទ្រព្យសម្បត្តិដែរ ហើយមានតម្លៃស្មើគ្នានឹងការបរិច្ចាគជាប្រាក់កាក់នៃតម្លៃសេដ្ឋកិច្ច។[56]

## ៣.២.ការបែងចែកកាតព្វកិច្ចបំណុលក្រោយការលែងលះ

នៅក្នុងការអនុវត្តជាក់ស្តែង ប្តីប្រពន្ធដែលលែងលះគ្នា ខណៈពេលដែលពួកគេត្រូវទទួលខុសត្រូវចំពោះបំណុលរួម មានករណីដែលប្តីប្រពន្ធធ្វើកិច្ចព្រមព្រៀងបែងចែកទ្រព្យសម្បត្តិរួម ដោយក្នុងនោះពួកគេព្រមព្រៀងគ្នាបែងចែកបន្ទុកទទួលខុសត្រូវចំពោះបំណុលរួមផងដែរ ដូចជាកំណត់ឱ្យប្តីជាអ្នកទទួលខុសត្រូវចំពោះបំណុលរួមតែម្នាក់ឯង ឬឱ្យប្តីប្រពន្ធទទួលបន្ទុកម្នាក់ ១ភាគ២ នៃបំណុលរួមជាអាទិ៍។ ភាគីបានស្នើសុំឱ្យតុលាការធ្វើការបែងចែកបន្ទុកក្នុងការទទួលខុសត្រូវចំពោះបំណុលរួម ការស្នើសុំ ឬតាមកិច្ចព្រមព្រៀងបែងចែកបំណុល នៅក្នុងសេចក្តីសម្រេចលែងលះ។ តាមច្បាប់បំណុលនេះ ជាបំណុលដែលប្តីប្រពន្ធត្រូវទទួលខុសត្រូវរួមគ្នា។ តើការព្រមព្រៀងនេះ ឬសេចក្តីសម្រេចបែងចែកបំណុលរួមមានអានុភាពតាមផ្លូវច្បាប់ដែរឬទេ?

ការព្រមព្រៀងបែងចែកបន្ទុកក្នុងការទទួលខុសត្រូវចំពោះបំណុលរួមរបស់ប្តីប្រពន្ធ ពុំមានអានុភាពតាមផ្លូវច្បាប់ឡើយ។ តុលាការមិនអាចសម្រេចតាមអ្វីដែលភាគីស្នើសុំបានទេ ពីព្រោះការទាមទាររបស់ភាគី ជាការទាមទារដែលមិនស្របច្បាប់ ហើយទោះបីជាមានករណីដែលតុលាការសម្រេចបែងចែកបន្ទុកក្នុងការទទួលខុសត្រូវបំណុលរួមរបស់ប្តីប្រពន្ធនៅក្នុងសេចក្តីសម្រេចលែងលះក៏ដោយ ក៏សេចក្តីសម្រេចនោះពុំបង្កើតអានុភាពតាមផ្លូវច្បាប់ឡើយ។ ហេតុផលគឺ៖

១. ប្តីប្រពន្ធត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ទោះបីជាបានធ្វើការលែងលះគ្នាក៏ដោយ ក៏នៅតែត្រូវទទួលខុសត្រូវរួមគ្នាដែរ ប្រសិនបើឱ្យប្តីប្រពន្ធធ្វើការបែងចែកបំណុលរួម ដូចជា ១ភាគ២ ម្នាក់ នឹងនាំឱ្យបំពានផលប្រយោជន៍របស់ម្ចាស់បំណុល (ផលប្រយោជន៍ដែលម្ចាស់បំណុលអាចប្តឹងទាមទារឱ្យទាំងប្តីទាំងប្រពន្ធឱ្យអនុវត្តកាតព្វកិច្ចទាំងអស់)។

២. ការសម្រេចក្នុងការចាត់ចែងបំណុលនោះបែបណា (ទាមទារពីប្តីទាមទារពីប្រពន្ធ ឬទាំងប្តីប្រពន្ធ ឬលើកលែងបំណុល) គឺជាសិទ្ធិសម្រេចរបស់ម្ចាស់បំណុល មិនមែនជាសិទ្ធិសម្រេចរបស់កូនបំណុលទេ ហេតុនេះប្តីប្រពន្ធជាកូនបំណុលមានកាតព្វកិច្ចសងបំណុលដោយរួមគ្នា ពុំអាចធ្វើការចាត់ចែងបំណុលនោះដោយខ្លួនឯងដោយការព្រមព្រៀងបែងចែកបំណុលបានទេ។

[55] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៩៨០ កថាខណ្ឌទី១ ចំណុចខ វាក្យខណ្ឌទី២។

[56] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា ៩៨០ កថាខណ្ឌទី៣។

## ៣.៣.សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន

សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន ជាប្រភេទមួយនៃអាហារកាតព្វកិច្ច ដោយផ្ដោតលើទំនាក់ទំនងឪពុកម្ដាយនិងកូន។ អ្នកមានអំណាចមេបាមានករណីយកិច្ចបីបាច់ថែរក្សាកូនជាអនីតិជន អប់រំកូន ប្រើប្រាស់អំណាចមេបាដោយសហការគ្នា និងមានករណីយកិច្ចបង់សោហ៊ុយនោះដោយសហការគ្នា ហើយការផ្គត់ផ្គង់ជីវភាពសម្រាប់កូនជាអនីតិជន។ ប្រសិនបើមានការលែងលះ កូនដែលជាអនីតិជននៅតែទទួលបានការបីបាច់ថែរក្សា ជាធម្មតាដូចមុនពេលលែងលះផងដែរ។ គោលបំណងនៃការបង្កើតបញ្ញត្តិស្តីពីសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន គឺដើម្បីថែរក្សាជីវភាពប្រចាំថ្ងៃរបស់កូនរហូតដល់ទទួលបាននីតិភាព។ ឪពុក ឬម្ដាយដែលគ្មានអំណាចមេបាក្រោយការលែងលះ ត្រូវបង់ប្រាក់ទៅឱ្យអ្នកមានអំណាចមេបា ដើម្បីយកធនធាននោះទៅបីបាច់ថែរក្សា គ្រប់គ្រងចិញ្ចឹមកូនរហូតបានទទួលនីតិភាព មានន័យថា សោហ៊ុយនេះអនុវត្តចំពោះកូនដែលជាអនីតិជន។ កូនដែលជាអនីតិជនត្រូវទទួលបានសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនពីឪពុកម្ដាយ។[57] ទោះបីនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬក្រោយការលែងលះក៏ដោយ។ ប៉ុន្តែប្រសិនបើមានការលែងលះ សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន តុលាការនឹងមិនសម្រេចទេ បើករណីមិនមានពាក្យសុំ។ មួយវិញទៀត តុលាការសម្រេចករណីនេះប្រសិនបើគូភាគីមិនបានព្រមព្រៀងគ្នា។ តើសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូនអាចបង់សរុបបានឬទេ? ចុះបើបង្គាប់ឱ្យបង់ប្រចាំខែ បើជនដែលមានករណីយកិច្ចមិនបង់ តើត្រូវធ្វើដូចម្ដេច? ករណីបែបនេះបើបុគ្គលណាមិនបង់ប្រាក់ ឬតាវកាលិកដែលកើតចេញពីសេចក្តីសម្រេចរឿងនេះ ប្រសិនបើយល់ឃើញថា សមរម្យតុលាការអាចចេញដីកាសម្រេចបង្គាប់ឱ្យអ្នកមានករណីយកិច្ច អនុវត្តករណីយកិច្ចនោះដោយកំណត់ពេលសមរម្យមួយតាមពាក្យសុំរបស់អ្នកមានសិទ្ធិបាន។[58] ជាក់ស្ដែងការបង់សរុបនៃសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រងថែរក្សាកូន គឺមិនត្រូវបានអនុញ្ញាតឡើយ តុលាការត្រូវពិចារណាអំពីប្រយោជន៍របស់កូនជាអាទិភាព។[59]

បើសម្រេចតាមការព្រមព្រៀងត្រូវផ្ដល់ហេតុផល មិនអាចយកហេតុផលតាមការព្រមព្រៀងនោះទេ តុលាការត្រូវសិក្សាចំណូលរបស់ឪពុក ចំណូលរបស់ម្ដាយ និងតម្រូវការប្រចាំខែរបស់កូនក្នុងការកំណត់អំពីចំនួនជាក់លាក់នៃប្រាក់ដែលត្រូវបង់។ បើសិនមានពាក្យសុំរបស់ភាគី តុលាការត្រូវសម្រេចទោះបីមានការព្រមព្រៀងរបស់គូភាគីក៏ដោយ ប៉ុន្តែតុលាការមិនមែនសម្រេចតាមការព្រមព្រៀងនោះទេ គឺសម្រេចតាមស្ថានភាពជាក់ស្ដែង។ តុលាការអាចសម្រេចដោយផ្អែកលើផលប្រយោជន៍របស់កូន តាមរយៈគោលការណ៍កូនជាអនីតិជនត្រូវទទួលបានសោហ៊ុយចាំបាច់នេះ ដោយសារកូនជាអ្នកទទួលការខូចខាតខ្លាំងជាងគេក្រោយការលែងលះ។

[57]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០៤០ កថាខណ្ឌទី១ និងច្បាប់ស្តីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, មាត្រា២២ កថាខណ្ឌទី១។

[58]ច្បាប់ស្តីពីបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល, មាត្រា២២។

[59]ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា១០១៤ កថាខណ្ឌទី៥ និងកថាខណ្ឌទី៦។

ជាសរុប ការអនុវត្តកាតព្វកិច្ចក្នុងការបង់សោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ត្រូវធ្វើជាដំណាក់កាល ឬជាប្រចាំ ដើម្បីធានានូវស្ថិរភាពនៃជីវភាពប្រចាំថ្ងៃរបស់កូន និងអាចបញ្ចៀសនូវបញ្ហានានាដែលអាចកើតមានឡើង ប្រសិនបើអ្នកមានអំណាចមេបាប្រើប្រាស់សោហ៊ុយរបស់កូនខុសគោលដៅនឹងនាំឱ្យជីវភាព និងផលប្រយោជន៍របស់កូន មិនត្រូវបានធានា ហើយអ្វីដែលតុលាការពិចារណាចម្បង ក្រោយការលែងលះគឺតម្កល់ផលប្រយោជន៍កូនជាអនីតិជន។ សោហ៊ុយចាំបាច់សម្រាប់ចញ្ចឹមកូន គឺសម្រាប់តែកូនប៉ុណ្ណោះ បើបង់ផ្ដាច់អាចមានហានិភ័យដល់កុមារ ព្រោះអ្នកមានអំណាចមេបាលើកូនអាចយកប្រាក់ដែលជាសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទៅប្រើប្រាស់ក្នុងគោលបំណងដែលមិនមែនជាប្រយោជន៍របស់កូននោះ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងបានបកស្រាយយ៉ាងលម្អិតទាក់ទងនឹងប្រធានបទស្តីពី "**សិទ្ធិ និងករណីយកិច្ចក្រោយពេលលែងលះក្នុងចំណងអាពាហ៍ពិពាហ៍**"រួចមកបានបង្ហាញថា ចំណុចចាប់ផ្តើមដែលនាំឱ្យមានការលែងលះ គឺមូលហេតុដែលកើតឡើងពីបញ្ហាដែលនាំឱ្យសហព័ទ្ធប្រាស់ចាកពីកម្មវត្ថុនៃការថែរក្សាចំណងអាពាហ៍ពិពាហ៍ឱ្យបានឋិតថេរគង់វង្ស។នៅពេលដែលសហព័ទ្ធរស់នៅបាត់បង់មនោសញ្ចេតនា និងរស់នៅមិនចុះសម្រុងគ្នានោះនាំឱ្យមានការលែងលះកើតឡើង។ សហព័ទ្ធមានសិទ្ធិក្នុងការរំលាយចំណងអាពាហ៍ពិពាហ៍នោះទៅវិញ ដោយការទាមទារលែងលះនៅតុលាការ។ សហព័ទ្ធ ត្រូវបង្ហាញតុលាការឱ្យឃើញពីកម្មវត្ថុ និងមូលហេតុនាំឱ្យកើតមានការលែងលះ។ មូលហេតុនៃការលែងលះអាចមានច្រើនប្រភេទ តែមូលហេតុទាំងនោះត្រូវតែមានលក្ខណៈសមហេតុសមផល ដូចដែលក្រមរដ្ឋប្បវេណីបានកំណត់។ តាមរយៈការស្រាវជ្រាវក្នុងប្រធានបទនេះ ការលែងលះចែកចេញជាពីរប្រភេទគឺការលែងលះដោយការព្រមព្រៀង និងការលែងលះដោយគ្មានការព្រមព្រៀង។

ចំពោះនីតិវិធីក្នុងការដោះស្រាយការលែងលះ គឺត្រូវអនុលោមទៅតាមនីតិវិធីរដ្ឋប្បវេណី គួបផ្សំជាមួយនឹងច្បាប់នីតិវិធីមួយចំនួនទៀតអាស្រ័យលើលក្ខខណ្ឌនៃការទាមទារលែងលះ។ បទដ្ឋានគតិយុត្តដែលត្រូវអនុលោមរួមជាមួយក្រមនីតិវិធីរដ្ឋប្បវេណី សម្រាប់ដោះស្រាយការលែងលះមានដូចជា៖ ច្បាប់ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ សម្រាប់ដោះស្រាយការលែងលះដោយការព្រមព្រៀង និងច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ សម្រាប់ការដោះស្រាយនៅក្នុងនីតិវិធីនៃលែងលះដោយគ្មានការព្រមព្រៀង។ ការលែងលះមានលក្ខណៈស្មុគស្មាញ មានការព្រមព្រៀងលើការបែងចែកសិទ្ធិអំណាចមេបា ទ្រព្យសម្បត្តិ សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន និងករណីយកិច្ចផ្សេងៗទៀតជាច្រើន។ អានុភាពនៃការលែងលះ គឺមានពាក់ព័ន្ធនឹងការបែងចែកផ្សេងៗ នៅក្រោយការលែងលះចំពោះភាគី។ ការកំណត់លើការបែងចែកទាំងនោះ តុលាការនឹងសម្រេចស្របតាមឆន្ទៈព្រមព្រៀងរបស់ភាគី។ តែផ្ទុយមកវិញ ប្រសិនបើភាគីមិនអាច ពិភាក្សាគ្នាបាន ក្នុងការសម្រេចបែងចែកផ្សេងទៀតទេ នោះតុលាការនឹងសម្រេចបែងចែកសិទ្ធិ និងករណីយកិច្ចទាំងនោះអាស្រ័យលើការកំណត់នៅក្នុងបញ្ញត្តិច្បាប់រដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។ គួរបញ្ជាក់ផងដែរមិនមែនរាល់ការប្តឹងទាមទារលែងលះទាំងអស់សុទ្ធតែទទួលបានការឯកភាពសម្រេចឱ្យភាគីលែងលះដោយតុលាការឡើយ។ នៅក្នុងករណីខ្លះ តុលាការសម្រេចបដិសេធមិនឲ្យមានការលែងលះដោយយល់ឃើញថា ការលែងលះនោះមានភាពមិនសុចរិត ឬការរកឃើញនូវឆន្ទៈមិនពិតប្រាកដរបស់ភាគីដែលទាមទារលែងលះ។

សរុបសេចក្តីមក ទាំងអស់ខាងលើនេះគឺជាការបង្ហាញនៅសិទ្ធិ និងករណីកិច្ចក្រោយការលែងលះ មូលហេតុដែលបង្កឱ្យមានការលែងលះ ការកំណត់ឱ្យបានអំពីអ្នកមានអំណាចមេបា ការបែងចែកទ្រព្យ

សម្បត្តិ សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន នៅពេលមានការលែងលះ ដើម្បីធានាដល់ការរស់នៅរបស់កូន ព្រោះថាឪពុកម្តាយត្រូវរស់នៅបែកគ្នា ចំណែកកូនត្រូវបានរស់នៅក្រោមការគ្រប់គ្រង មើលថែរបស់ឪពុក ឬម្តាយតែម្ខាងប៉ុណ្ណោះ ដូច្នេះប្រាកដណាស់ កូននឹងត្រូវរស់នៅដោយខ្វះភាពកក់ក្តៅពីឪពុក ឬម្តាយម្ខាងទៀត។ ដូចនេះហើយ ប្រសិនបើមានការលែងលះ ការសម្រេចឱ្យបានអំពីអ្នកមានអំណាចមេបាសម្រាប់កូន ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីឱ្យកូនបានរស់នៅជាមួយអ្នកដែលអាចចិញ្ចឹមបីបាច់មើលថែឱ្យបានល្អ ម្យ៉ាងការដែលកំណត់អំពីអំណាចមេបាដ៏ល្អមួយសម្រាប់កូន គឺជាការយន្តការមួយដ៏សំខាន់ ព្រោះមិនសូវជាជះឥទ្ធិពលអាក្រក់ខ្លាំងដល់ផ្លូវចិត្តរបស់កូន និងមិនប៉ះពាល់ខ្លាំងដល់ប្រយោជន៍កូន ក្រោយពីឪពុកម្តាយត្រូវបានផ្តាច់នូវចំណងអាពាហ៍ពិពាហ៍។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវអំពីប្រធានបទ "**សិទ្ធិនិងករណីយកិច្ចក្រោយពេលលែងលះក្នុងចំណងអាពាហ៍ពិពាហ៍**" រួចមក នាងខ្ញុំសង្កេតឃើញថា ក្រោយការលែងលះ គឺមានលក្ខណៈស្មុគស្មាញជាច្រើន មិនតែប៉ុណ្ណោះក្រោយការលែងលះថែមទាំងបានបន្សល់នូវគុណវិបត្តិជាច្រើនដល់សង្គមជាតិ ដល់ភាគីលែងលះ និងដល់បុគ្គលពាក់ព័ន្ធផ្សេងទៀត ជាពិសេសគឺកូនៗ របស់សហព័ទ្ធដែលសម្រេចចិត្តលែងលះគ្នា។ ការខាតបង់ដែលបង្កមកពីការលែងលះមានច្រើនយ៉ាងដូចជា៖ ការខាតបង់ទ្រព្យសម្បត្តិ ការខាតពេលវេលា ពិសេសគឺការប៉ះពាល់ទៅដល់កិត្តិយសក្រុមគ្រួសារ។ ជាចុងក្រោយ យើងខ្ញុំសូមការអនុញ្ញាតលើកឡើងនូវអនុសាសន៍មួយចំនួនដូចខាងក្រោម ក្នុងគោលបំណង និងឆន្ទៈដើម្បីធ្វើឱ្យស្នាដៃមួយនេះអាចយកទៅអនុវត្តឱ្យបានសមស្របទៅនឹងស្ថានភាពនិងកាលៈទេសៈជាក់ស្តែង ក៏ដូចជាការកាត់បន្ថយការលែងលះក្នុងសង្គម។

- ចំពោះប្តីប្រពន្ធ ទាំងអស់ដែលរៀបអាពាហ៍ពិពាហ៍គួរគប្បីមានការខន្តី យោគយល់ និងអធ្យាស្រ័យដល់គ្នាឱ្យបានច្រើន ព្រមទាំងមេត្តាគិតគូរឱ្យបានវែងឆ្ងាយមុននឹងសម្រេចចិត្តលែងលះ ពីព្រោះថាការលែងលះបន្សល់ទុកនូវគុណវិបត្តិ និងព្យសនកម្មជាច្រើន។
- ទោះបីជាប្រទេសកម្ពុជា យើងមានច្បាប់គ្រប់គ្រាន់ក្នុងការដោះស្រាយនៅពេលមានការលែងលះរួចហើយក្តី ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវតែធ្វើការផ្សព្វផ្សាយដល់ពលរដ្ឋខ្មែរ ឱ្យមានការយល់ដឹងកាន់តែច្បាស់ និងទូលំទូលាយបន្ថែមទៀតអំពីការលែងលះ ព្រោះបច្ចុប្បន្ននេះនៅមានប្រជាពលរដ្ឋខ្មែរមួយចំនួននៅពុំទាន់បានយល់ច្បាស់ ឬនៅមានការភាន់ច្រឡំនៅឡើយ។
- ស្ថាប័នមានសមត្ថកិច្ច គឺស្ថាប័នតុលាការដែលមានយុត្តាធិការទៅលើរឿងក្តីលែងលះ សូមធ្វើការដឹកនាំនីតិវិធី និងដោះស្រាយរឿងក្តីលែងលះឱ្យប្រព្រឹត្តទៅបានលឿន ពីព្រោះថាចំណាត់ការយឺតយ៉ាវអាចនឹងបង្កឱ្យកើតមានផលប៉ះពាល់កាន់តែច្រើនទៅលើប្រយោជន៍ភាគី ជាពិសេសនោះ គឺប៉ះពាល់ដល់ផលប្រយោជន៍របស់កូនៗ ដែលកំពុងរង់ចាំការសម្រេចអំពីអំណាចមេបា។
- បញ្ហាអនុវត្តសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន តុលាការបានកំណត់ឱ្យឪពុក ឬម្តាយ ដែលពុំមានអំណាចមេបាជួបប្រាស្រ័យទាក់ទងជាមួយកូន តាមវិធីដូចមានកំណត់នៅក្នុងសេចក្តីសម្រេច ប៉ុន្តែអ្នកមានអំណាចមេបាមិនព្រមអនុវត្តឱ្យបានពេញលេញដូចអ្វីដែលមានកំណត់នៅក្នុងសេចក្តីសម្រេច ដែលធ្វើឱ្យខកខានការជួប និងប្រាស្រ័យទាក់ទងកូន ហេតុនេះ គួរតែមានការដាក់មន្ត្រីដែលសមត្ថកិច្ចដើម្បីតាមដាននូវការអនុវត្តសិទ្ធិរបស់អ្នកមានអំណាចមេបាចំពោះកូននៅរយៈពេលដែលគេអនុវត្តសិទ្ធិទៅតាមសេចក្តីសម្រេចឱ្យបានត្រឹមត្រូវ។

# ឯកសារយោង

# ឯកសារយោង


## ១. ច្បាប់

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកម/០៥១១/០០៧, ៣១ ឧសភា ២០១១។

ច្បាប់ស្តីពីនីតិវិធីនៃរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង, លេខ នស/រកម/០៧១០/០១៣, ១០ កក្កដា ២០១០។

ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល, នស/រកម/១១២០/០០៨, ០៨ មិថុនា ២០១០។

ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ស្តីពីឯកពន្ធភាព, លេខ នស/រកម/១០០៦/០២៦, ០១ កញ្ញា ២០០៦។

## ២. សៀវភៅសិក្សា

រុន ពណ្ណារិទ្ធ. ២០២៣. នីតិគ្រួសារ (បង្រៀនឆ្នាំទី១ ឆមាសទី២. សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច)។

មេធាវី អ៊ីវ ប៉ូលី. ០១ ធ្នូ ២០១១. នីតិរដ្ឋប្បវេណី (មេរៀនសង្ខេប)។

សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ៣ រៀបរាងដោយ ក្រុមការងារនៃគ្រូបង្គោលនៃសាលាភូមិន្ទចៅក្រម ការកែសម្រួលលើការបោះពុម្ពលើកទី ១, ភ្នំពេញ ខែ មីនា ឆ្នាំ ២០១៧។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី.២០១០. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី. ភាគ៥, គន្ថីទី៧. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី.២០០៩. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី. ភាគ១, គន្ថីទី១-ទី៣. ភ្នំពេញ៖ ក្រសួងយុត្តិធម៌។

## ៣.គេហទំព័រ

https://youtu.be/dPXeRFGFcel?si=SMr51AD3ih8g9OJg (ចូលទស្សនាថ្ងៃទី ២៤ខែ មិថុនា ឆ្នាំ ២០២៤)។

https://www.facebook.com/share/p/k3fDHpUXJi2nL6LM/?(ចូលទស្សនាថ្ងៃទី ២០ខែ មិថុនា ឆ្នាំ ២០២៤)។

https://pdfreader.page.link/shareapp (ចូលទស្សនាថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២៤)។

https://youtu.be/fYy-6AJV_fQ?si=n0fcD4keQ_IPCZFh (ចូលទស្សនាថ្ងៃទី១៤ ខែ មិថុនា ឆ្នាំ២០២៤)។

# ឧបសម្ព័ន្ធ

13/7

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
សាលក្រមលេខ:០៩(ម)/១២១
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤

*រឿងក្តីរដ្ឋប្បវេណីលេខ ០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤*
*ប្រភេទនៃរឿងក្តី ៖ បណ្តឹងសុំលែងលះ*
*បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤*
*ថ្ងៃខែឆ្នាំប្រកាសសាលក្រម: ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២៤*

**គាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តសៀមរាប**

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រម នៃសាលាដំបូង ខេត្តសៀមរាប

-លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូង ខេត្តសៀមរាប

បានចេញសាលក្រមដែលមានភាគី៖

**ដើមចោទ៖**

-ឈ្មោះ [redacted] ភេទស្រី កើតឆ្នាំ១៩៨៨ អាសយដ្ឋាននៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ វត្តមាន

មានលោក [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទ ។ វត្តមាន

**ចុងចម្លើយ ៖**

-ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ១៩៨៦ អាសយដ្ឋាននៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។ អវត្តមាន

មានលោក [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ ។ វត្តមាន

**អង្គហេតុ និង ចំណុចវិវាទ**

១-សាលក្រមដែលទាមទារដោយដើមចោទ

<u>ការទាមទាររបស់ដើមចោទ៖</u>

១-សុំឲ្យដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] លែងលះពីគ្នា ។

២-ឲ្យដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាក្នុងការមើលថែរក្សាគ្រប់គ្រងកូនចំនួន២នាក់ កូនទី១ឈ្មោះ [redacted] ទេពនេត្រា ភេទស្រី កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ និងកូនទី២ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ។

៣-សុំបែងចែកទ្រព្យសម្បត្តិរួមដូចជា៖

ក.ប្រគល់ឲ្យដើមចោទនូវ៖

-ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-៣៤២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៩ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដីពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ ៥៣៦ ឈ្មោះ [redacted] ខាងត្បូងជាប់ក្បាលដីលេខ ៥៣៣ ឈ្មោះ [redacted] ខាងកើតជាប់ក្បាលដីលេខ ៥៣៤ ឈ្មោះ [redacted] ខាងលិចជាប់ផ្លូវ ។

ខ.ប្រគល់ឲ្យចុងចម្លើយនូវ

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៥៣៧ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៨ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ១៣៨ មានទីតាំងស្ថិតនៅភូមិអូរឫស្សី ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

៨-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

**២-ការសង្ខេបរឿង ៖**

គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធ ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ០៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំបាក់ចិញ្ចៀន ស្រុកក្រវាញ ខេត្តពោធិ៍សាត់ ។ ជាចំណងដៃអាពាហ៍ពិពាហ៍ គូភាគីមានកូនចំនួន ២នាក់ កូនទី១ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ និងកូនទី២ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ។ មូលហេតុនៃការលែងលះ ដោយការរស់នៅជាមួយគ្នាកន្លងមកពុំសូវមានសុភមង្គលទេ តែងតែមានភាពរកាំរកូសឈ្លោះទាស់ទែងគ្នាជាញឹកញាប់ ហើយការរស់នៅមិនមានភាពចុះសម្រុងជាមួយគ្នា ព្រមទាំងរស់នៅបែកលំនៅសង្វាសពីគ្នា ដែលជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធនិងគ្នាតទៅទៀត ។

គូភាគីមានទ្រព្យសម្បត្តិរួមមួយចំនួនដូចជា៖

-ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-៣៨២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រគល់ក្បាលដីលេខ ៣២៩ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៨ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៥៣៧ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ១៣៨ មានទីតាំងស្ថិតនៅភូមិអូរឫស្សី ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

-ដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដីពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ ៥៣៦ ឈ្មោះ [redacted] ខាងត្បូងជាប់ក្បាលដីលេខ ៥៣៣ ឈ្មោះ [redacted] ខាងកើតជាប់ក្បាលដីលេខ ៥៣៤ ឈ្មោះ [redacted] ខាងលិចជាប់ផ្លូវ ។

៣-ចំណុចគ្មានវិវាទ ៖ គូភាគីព្រមព្រៀងលែងលះ ។

៤-ចំណុចមានវិវាទ ៖

-ដើមចោទទាមទារសិទ្ធិអំណាចមេបាចិញ្ចឹមកូនទាំងពីរនាក់ និងចុងចម្លើយទាមទារសិទ្ធិអំណាចមេបាចិញ្ចឹមកូនម្នាក់ ។

-ការបែងចែកទ្រព្យសម្បត្តិរវាងដើមចោទនិងចុងចម្លើយ ។ 13/5

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា ៖

គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្ដីប្រពន្ធ ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ០៩ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១១ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំបាក់ចិញ្ចៀន ស្រុកក្រវាញ ខេត្តពោធិ៍សាត់ ។ ជាចំណងដៃអាពាហ៍ពិពាហ៍ គូភាគីមានកូនចំនួន ២នាក់ កូនទី១ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ និងកូនទី២ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ។ មូលហេតុនៃការលែងលះ ដោយការរស់នៅជាមួយគ្នាកន្លងមកពុំសូវមានសុភមង្គលទេ តែងតែមានភាពរកាំរកូស ឈ្លោះទាស់ទែងគ្នាជាញឹកញាប់ ហើយការរស់នៅមិនមានភាពចុះសម្រុងជាមួយគ្នា ព្រមទាំងរស់នៅបែកលំនៅសង្វាសពីគ្នា ដែលជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាប្ដីប្រពន្ធនិងគ្នាតទៅទៀត។ គូភាគីមានទ្រព្យសម្បត្តិរួមមួយចំនួនដូចជា៖

-ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-៣៤២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៩ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៨ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៥៣៧ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ១៣៥ មានទីតាំងស្ថិតនៅភូមិអូរឫស្សី ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

-ដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដី ពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ ៥៣៦ ឈ្មោះ [redacted] ខាងត្បូងជាប់ក្បាលដីលេខ ៥៣៣ ឈ្មោះ គួ ស៊ីវខេង ខាងកើតជាប់ក្បាលដីលេខ ៥៣៤ ឈ្មោះ [redacted] ខាងលិចជាប់ផ្លូវ ។

ដើមចោទឈ្មោះ [redacted] បានធ្វើសេចក្ដីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា៖ ខ្លួនសុំលែងលះពីចុងចម្លើយឈ្មោះ [redacted]។ មូលហេតុខ្លួនសុំលែងលះពីចុងចម្លើយ គឺការរស់នៅជាមួយគ្នាកន្លងមកពុំសូវមានសុភមង្គលទេ តែងតែមានការរកាំរកូសឈ្លោះទាស់ទែងគ្នាជាញឹកញាប់ មិនជួយធ្វើការ ជេរប្រមាថខ្លួន និងកូន មិនផ្គត់ផ្គង់គ្រួសារ មិនជួយមើលថែកូន និងបានរស់នៅឆ្ងាយពីគ្នាចាប់តាំងពីអំឡុងឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ដែលជាហេតុធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នាតទៅទៀតបានទេ ។ ខ្លួនសុំសិទ្ធអំណាចមេបាលើកូនចំនួន២នាក់ កូនទី១ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០១៣ និងកូនទី២ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ដោយហេតុថា ខ្លួនជាម្ដាយអាចមើលថែកូនបានល្អ ផ្ដល់ភាពកក់ក្ដៅ និងមានសមត្ថភាពផ្គត់ផ្គង់កូនបានយ៉ាងល្អ។ ខ្លួនសុំសិទ្ធិគ្រប់គ្រងនូវដីដូចខាងក្រោម៖

-ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-៣៤២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៩ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដី ពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ មានព្រំប្រទល់ខាងជើងជាប់ក្បាលដីលេខ ៥៣៦ ឈ្មោះ [redacted] ខាងត្បូងជាប់ក្បាលដីលេខ ៥៣៣ ឈ្មោះ [redacted] ខាងកើតជាប់ក្បាលដីលេខ ៥៣៤ ឈ្មោះ [redacted] ខាងលិចជាប់ផ្លូវ ។

-ខ្លួនប្រគល់ឲ្យចុងចម្លើយនូវដី ៖

-ក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៨ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៥៣៧ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ១៣៤ មានទីតាំងស្ថិតនៅភូមិអូរឫស្សី ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសុំរក្សាសេចក្តីថ្លែងការណ៍ដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងសេចក្តីថ្លែងការណ៍របស់ដើមចោទ ទុកជាបានការដដែល ។

ចុងចម្លើយឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា៖ ខ្លួនព្រមលែងលះពីដើមចោទ ។ ខ្លួនសុំសិទ្ធិអំណាចមេបាចិញ្ចឹមកូនមួយនាក់ ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ព្រោះខ្លួនអាចចិញ្ចឹមមើលថែកូន និងឲ្យកូនទៅរៀនបានយ៉ាងល្អ ។ ខ្លួនមានលទ្ធភាពចិញ្ចឹមបីបាច់ថែរក្សាកូនព្រោះខ្លួនមានផ្ទះផ្ទាល់ខ្លួន និងមានឪពុកម្តាយបងប្អូនជួយមើលថែកូន។ ចំពោះទ្រព្យសម្បត្តិរួមដែលដើមចោទបានលើកឡើង ខ្លួនទទួលស្គាល់ដូចការលើកឡើងរបស់ដើមចោទ និងសុំបែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម ៖ -ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-៣៤២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប សុំចែកជាពីរចំណែកស្មើគ្នា ។

ចំណែកដីដែលមានក្បាលដីលេខ ៣២៨ , ៣២៩ ដីទាំង២នេះអាចប្តូរជាមួយនឹងដីដែលមានក្បាលដីលេខ ៥៣៧ ដីទាំងបីកន្លែងនេះខ្លួនទុកសិទ្ធិឲ្យដើមចោទជ្រើសរើសមុន ។

ចំណែកក្បាលដីលេខ ១៣៤ និងដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដី ពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ចែកជាពីរចំណែកស្មើគ្នា ។

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ ធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីរបស់ខ្លួនសុំរក្សាការទាមទារដែលមានសេចក្តីថ្លែងការណ៍ក្នុងគ្រប់នីតិវិធី ទុកជាបានការដដែល ។

-ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា ការរស់នៅមិនចុះសម្រុងគ្នា ដោយមូលហេតុថាមិនយល់អំពីគ្នាទៅវិញទៅមក ហើយតែងឈ្លោះប្រកែកគ្នាជាញឹកញាប់ ពួកខ្លួនព្រមព្រៀងលែងលះគ្នា ។ 13/3

-យល់ឃើញថា ឆ្លងតាមការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ អាចបញ្ជាក់បានថា សហព័ទ្ធបានរស់នៅមិនចុះសម្រុងនឹងគ្នា ហើយតែងតែមានរកាំរកូសជាមួយគ្នាជាញឹកញាប់ ធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាមិនអាចរស់ជាប្តីប្រពន្ធ ជាមួយនឹងចុងចម្លើយតទៅទៀតបាន ដែលជាបញ្ហាប្រឈម ធ្វើឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយក៏គ្មានលទ្ធផលនឹងសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាន ដូច្នេះតុលាការ គប្បីពិចារណាលើការសុំលែងលះរបស់ភាគីដើមចោទ តាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

-យល់ឃើញថា ដើមចោទបានសុំសិទ្ធិអំណាចមេបាលើកូនចំនួន២នាក់ កូនទី១ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣ និងកូនទី២ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ចំនែកចុងចម្លើយ ក៏បានទាមទារសិទ្ធិអំណាចចិញ្ចឹមកូនម្នាក់ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ដែរ ។ ក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់កូនឈ្មោះ [redacted] ភេទស្រី បានរើសយកការរួមរស់ជាមួយម្តាយ ចំនែកកូនឈ្មោះ [redacted] ភេទស្រី បានរើសយកការរួមរស់ជាមួយឪពុក ដូច្នេះ តុលាការសម្រេចតាមការជ្រើសរើសរបស់កូនទាំងពីរនាក់។

-យល់ឃើញថា ចំពោះ អាហារកាតព្វកិច្ចចិញ្ចឹមកូនគឺគូភាគីបានឯកភាពគ្នា មិនទាមទារពីគ្នានោះទេ ដូច្នេះ គប្បីសម្រេចអោយគូភាគីផ្តល់អាហារកាព្វកិច្ចកូនតាមលទ្ធភាព។

-យល់ឃើញថា ដើមចោទទាមទារដីចំនួនបីកន្លែង ៖

-ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ១៧១០០២០៩-៣៤២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៩ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដី ពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ដោយសំអាងថា ក្រោយពីលែងលះពីចុងចម្លើយ ខ្លួនក្លាយជាស្ត្រីមេម៉ាយ ត្រូវចិញ្ចឹមមើលថែកូនតែម្នាក់ឯង ម្យ៉ាងទៀត ខ្លួនបានបែកលំនៅឋានជាមួយចុងចម្លើយ ត្រូវមករស់នៅផ្ទះជួលខាងក្រៅ ត្រូវមានបន្ទុកជាច្រើនសម្រាប់ផ្គត់ផ្គង់ជីវភាព ឃើញថាការអះអាងរបស់ដើមចោទមានហេតុផលសមរម្យ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

យល់ឃើញថា ចុងចម្លើយទាមទារបែងចែកដីដូចខាងក្រោម:

-ដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០២០៩-៣៤២១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានទីតាំងស្ថិតនៅភូមិគ្រួស សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប សុំចែកជាពីរចំណែកស្មើគ្នា ។

ចំណែកដីដែលមានក្បាលដីលេខ ៣២៨ , ៣២៩ ដីទាំង២នេះអាចប្តូរជាមួយនឹងដីដែលមានក្បាលដីលេខ ៥៣៧ ដីទាំងបីកន្លែងនេះខ្លួនទុកសិទ្ធិឲ្យដើមចោទជ្រើសរើសមុន ។

-ដីទំហំ ៦x៣៨ម៉ែត្រ នៅសល់ពីការលក់ដីទៅឲ្យឈ្មោះ [redacted] មិនទាន់បានបំបែកប្លង់ដីពីបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ៥៣៥ មានទីតាំងស្ថិតនៅភូមិដំណាក់អំពិល ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។

ខ. ប្រគល់ឲ្យចុងចម្លើយនូវ៖

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៣២៨ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានក្រដាសបញ្ជាក់ព្រំប្រទល់ក្បាលដីលេខ ៥៣៧ មានទីតាំងស្ថិតនៅភូមិតាចក សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប ។

-ដីដែលមានបង្កាន់ដៃបញ្ជាក់ក្បាលដីលេខ ១៣៥ មានទីតាំងស្ថិតនៅភូមិអូរឬស្សី ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។

V.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០២៤ ចំពោះមុខគូភាគី និងប្រកាសជាសាធារណៈ នៅថ្ងៃ អង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃ១២ ខែ មីនា ឆ្នាំ២០២៤ ។

ថ្ងៃ អង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស .២៥៦៧

សៀមរាប,ថ្ងៃទី១២ ខែ មីនា ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

ឡុយ ចាន់ត្រា

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង
ខេត្តបន្ទាយមានជ័យ

សាលក្រមរដ្ឋប្បវេណី
-លេខ ២០១/១១-ច-
ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២៣
-សំណុំរឿងរដ្ឋប្បវេណីលេខ ៧៨
ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២៣ នៅសាលសវនាការនៃសាលាដំបូងខេត្តបន្ទាយមានជ័យ លើសំណុំរឿងរដ្ឋប្បវេណី លេខ ៧៨ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដោយមានសមាសភាពដូចតទៅ៖

### ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមនៃសាលាដំបូងខេត្តបន្ទាយមានជ័យ

### ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted] ជាក្រឡាបញ្ជីនៃសាលាដំបូងខេត្តបន្ទាយមានជ័យ

-ដើមចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣០ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានសង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

មេធាវីតំណាងដោយអាណត្តិលោក [redacted] អត្តលេខ ១៤៧៤ ជាសមាជិកនៃគណៈមេធាវីកម្ពុជា ។

-ចុងចម្លើយឈ្មោះ [redacted] ភេទស្រី អាយុ ២៩ឆ្នាំ សញ្ជាតិខ្មែ មានអាសយដ្ឋាននៅផ្ទះជួល ភូមិហ្គោដ្ឋាន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

មេធាវីតំណាងដោយអាណត្តិ [redacted] អត្តលេខ ៣២៤ ជាសមាជិកនៃគណៈមេធាវីកម្ពុជា ។

### អង្គហេតុ និង ចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ៖

១. សុំលែងលះប្រពន្ធឈ្មោះ [redacted] អាយុ ២៩ឆ្នាំ ។

២. សុំសិទ្ធិមានអំណាចមេបាលើកូនម្នាក់ឈ្មោះ [redacted] កើតឆ្នាំ២០១៧ និងកូនស្រីឈ្មោះ [redacted] កើតឆ្នាំ២០២១ ប្រគល់ឱ្យចុងចម្លើយឈ្មោះ [redacted] ជាអ្នកចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់ប្រាក់អាហារកិច្ចតាមលទ្ធភាព ។

៣.សុំបែងចែកទ្រព្យរួមជាពីរចំណែក ។

៤.ម៉ូតូចំនួន ០៣គ្រឿងទី១ ម៉ាក ហុងដា ភីស៊ីអិច ពណ៌ស ក្រហម ឆ្នាំ២០២០ ទី២ យ៉ាម៉ាហា ស៊្វីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និងទី៣ ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅ ។

៥.គ្រឿងអលង្ការ ០១ឈុត សរុបជាប្រាក់ចំនួន ១៩,៥០០ដុល្លារអាមេរិក(មួយម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក)។

៦.លុយក្នុងទូរដែកចំនួន ៥,៥០០ដុល្លារ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក)

ឆ្នាំ២០០៧ កូនក្តីខ្លួនព្រមឱ្យចុងចម្លើយ រីឯប្រាក់ចំនួន ១១ម៉ឺនដុល្លារក្នុងគណនី អេស៊ីលីដា ដែលដើមចោទបានអះអាង នោះគឺគ្មានទេ មានតែលុយខ្មែរចំនួន ២៦៥៦៦២រៀលប៉ុណ្ណោះ ចំណែក ម៉ូតូចំនួន ០៣គ្រឿងទី១ ម៉ាក ហុងដា ភីស៊ីអិច ពណ៌ស ក្រហម ឆ្នាំ២០២០ ទី២ យ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និងទី៣ ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅពិត ជាធ្លាប់មានមែន សព្វថ្ងៃនៅសល់តែពីរប៉ុណ្ណោះ គឺយ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និង ម៉ាក ហុងដា វេវ ពណ៌ ក្រហមខ្មៅ ចំណែកម៉ូតូហុងដាភីស៊ីអិច កូនក្តីខ្លួនបានលក់បាត់ហើយដោយសារមានគ្រោះថ្នាក់ចរាចរណ៍ តាំងពីមុន បែកគ្នា កូនក្តីខ្លួនសុំគ្រប់គ្រងម៉ូតូដែលនៅសល់ចំនួន ២គ្រឿង ។ ចំពោះគ្រឿងអលង្ការ តម្លៃ ១៩៥០០ដុល្លារ គឺគ្មាន ទេ ចំណែកលុយនៅក្នុងទូរដែក ចំនួន ៥៥០០ក៏គ្មានដែរ នៅក្នុងទូរដែកមានតែឯកសារដីធ្លីប៉ុណ្ណោះ។

-ចុងចម្លើយឈ្មោះ [redacted] បានថ្លែងការណ៍តបថា ៖

ទ្រព្យសម្បត្តិដែលខ្លួនមានសព្វថ្ងៃនេះជាទ្រព្យដែលកើតចេញពីការរកស៊ីរបស់ខ្លួន និងដេញតុងទីន ។ ខ្លួនជាអ្នក លក់ផ្លែឈើ របរលក់ផ្លែឈើនេះ ជារបរ របស់ប្តីប្រពន្ធខ្លួន ប្តីខ្លួនជាអ្នកដឹកខ្លួនមកលក់ផ្លែឈើ និងដឹកផ្លែឈើឱ្យខ្លួនលក់ របរលក់ផ្លែឈើរបស់ខ្លួន គឺខ្លួនលក់ផ្លែឈើតាំងពីមុនពេលរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទ ចំពោះកុងធនាគារ អេស៊ីលីដា ខ្លួនមានកុងធនាគារតាំងពីឆ្នាំ ២០០៨ ហើយខ្លួនបានរៀបការជាមួយចុងចម្លើយកាលពីឆ្នាំ ២០១៥ ខ្លួនសុំ បដិសេធថាគ្មានប្រាក់នៅក្នុងគណនីធនាគារចំនួន ៤៤០លានរៀលទេ ។

**៥.ចំណុចវិវាទ៖**

នៅក្នុងអង្គហេតុនៃសំណុំរឿងនេះ ដើមចោទសុំឱ្យតុលាការបែងចែកដី និងទ្រព្យសម្បត្តិផ្សេងៗទៀតដែល មានទីតាំងដូចខាងក្រោម៖

-ដីមានលេខក្បាលដី ៥៩១ ក.សរភ ស្ថិតនៅភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដើមចោទសុំឱ្យតុលាការបែងចែងតាមច្បាប់ ប៉ុន្តែចុងចម្លើយសុំប្រគល់ឱ្យដើមចោទ ។

-ដីមានក្បាលដីលេខ ៦៩៦ ក.សរភ នៅភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដើមចោទសុំឱ្យតុលាការបែងចែងតាមច្បាប់ ប៉ុន្តែចុងចម្លើយសុំប្រគល់ឱ្យដើមចោទ ។

-ដីនៅស្រុកប្រាសាទបាគង ខេត្តសៀមរាប មានក្បាលដីលេខ ២៣៦៨ ដើមចោទសុំឱ្យតុលាការបែងចែង តាមច្បាប់ ប៉ុន្តែចុងចម្លើយសុំប្រគល់ឱ្យដើមចោទ ។

-ដីភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើមចោទសុំឱ្យតុលាការ បែងចែងតាមច្បាប់ ប៉ុន្តែចុងចម្លើយសុំសិទ្ធិគ្រប់គ្រងលើដីនោះ ។

-ដីនៅភូមិសន្តិភាព ឃុំពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើមចោទសុំឱ្យតុលាការបែងចែងតាមច្បាប់ ប៉ុន្តែចុងចម្លើយសុំសិទ្ធិគ្រប់គ្រងលើដីនោះ ។

-ឡាន កាមេរី០៧ ពណ៌ស ផលិតឆ្នាំ២០០៧ ដើមចោទសុំឱ្យតុលាការបែងចែងតាមច្បាប់ ប៉ុន្តែចុងចម្លើយ សុំបែងចែកជាពីរចំណែក ។

-ប្រាក់ចំនួន ១១ម៉ឺនដុល្លារក្នុងគណនី អេស៊ីលីដា ដើមចោទសុំឱ្យតុលាការបែងចែងតាមច្បាប់ ប៉ុន្តែចុង ចម្លើយបដិសេធថាគ្មានប្រាក់នោះទៀតទេ ។

-ម៉ូតូចំនួន ០៣គ្រឿងទី១ ម៉ាក ហុងដា ភីស៊ីអិច ពណ៌ស ក្រហម ឆ្នាំ២០២០ ទី២ យ៉ាម៉ាហា ស៊ីរូស ពណ៌ ខ្មៅ ឆ្នាំ២០២១ និងទី៣ ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅ ដើមចោទ សុំបែងចែកតាមច្បាប់ ប៉ុន្តែចុងចម្លើយបាន

39/18

អះអាងថាម៉ូតូចំនួន ០៣គ្រឿងទី១ ម៉ាក ហុងដា ភីស៊ីអិច ពណ៌ស ក្រហម ឆ្នាំ២០២០ ទី២ យ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និងទី៣ ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅពិតជាធ្លាប់មានមែន សព្វថ្ងៃនៅសល់តែពីរប៉ុណ្ណោះ គឺយ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និង ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅ ចំណែកម៉ូតូហុងដាភីស៊ីអិច ខ្លួនលក់បាត់ទៅហើយ ដោយសារមានគ្រោះថ្នាក់ចរាចរណ៍ តាំងពីមុនបែកគ្នា ដើមចោទបដិសេធថា មុនពេលខ្លួនចេញទៅម៉ូតូម៉ាកភីស៊ីអិច នៅមាននៅឡើយ ។

-គ្រឿងអលង្ការ ០១ឈុត សរុបជាប្រាក់ចំនួន ១៩,៥០០ដុល្លារអាមេរិក(មួយម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) រួមមានខ្សែដៃមាសជិត ពីរតម្លឹង ,ជញ្ជៀនពេជ្រពីរវង្ស ,បន្តោងខ្សែករពេជ្រពីរបន្តោង ,ក្រវិលពេជ្រពីរគូ , ខ្សែករផ្កាកទិន ជិតពីរតម្លឹង ខ្សែករមាសចំនួន ២ខ្សែ សរុបពីរតម្លឹង ដើមចោទសុំបែងចែកតាមច្បាប់ ប៉ុន្តែចុងចម្លើយបដិសេធថាគ្មានទេ ។

-លុយក្នុងទូរដែកចំនួន ៥,៥០០ដុល្លារ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក) ដើមចោទសុំបែងចែកតាមច្បាប់ ប៉ុន្តែចុងចម្លើយបដិសេធថាគ្មានទេ ។

## ការពិនិត្យភស្តុតាង

-ដើមចោទបានស្នើសុំផ្តល់ភស្តុតាងជូនតុលាការពិនិត្យដូចខាងក្រោម៖

១.របាយការណ៍គណនី ដក-ដាក់សាច់ប្រាក់ របស់គ្រឹះស្ថាន អង្គរ មីក្រូហិរញ្ញវត្ថុ(កម្ពុជា)ហៅកាត់ AMK ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ។

២.លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ។

៣.លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ ។

៤.បញ្ជីលេខកូដក្បាលដីភូមិសន្តិភាព ឆ្នាំ២០១៩ លេខ ១៩៩/១៩ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ ។

៥.ប័ណ្ណសម្គាល់យានជំនិះ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការសាកសួរសាមីភាគី និងតាមការពិនិត្យភស្តុតាងឃើញថា៖

១.តាមការពិនិត្យពាក្យបណ្តឹង និងសេចក្តីថ្លែងការណ៍របស់គូភាគី ឃើញថា អ្នកទាំងពីរបានរួមរស់ជាមួយគ្នាតាំងពីឆ្នាំ២០១៦ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ គឺរស់នៅជាមួយគ្នាបែបអនីតិសង្វាស ឃើញថាការទាមទាររបស់ដើមចោទមិនត្រឹមតាមគតិច្បាប់ឡើយ គប្បីតុលាការច្រានចោលការទាមទារចំណុចទីមួយស្តីពីការលែងលះ ។

២.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] និងសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted]បានបញ្ជាក់ថា ក្នុងអំឡុងចំណងអាពាហ៍ពិពាហ៍ អ្នកទាំងពីរមានកូនចំនួនពីរនាក់ ឈ្មោះ [redacted] ភេទប្រុស កើតឆ្នាំ២០១៧ និងកូនស្រីឈ្មោះ[redacted] កើតឆ្នាំ២០២១ ប្រាកដមែន ។

៣.តាមការពិនិត្យរបាយការណ៍គណនីដក ដាក់សាច់ប្រាក់ របស់គ្រឹះស្ថាន អង្គរ មីក្រូហិរញ្ញវត្ថុ(កម្ពុជា) ហៅកាត់ AMK ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ និងតាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] បានបញ្ជាក់ សហព័ទ្ធទាំងពីរពិតជាធ្លាប់មានប្រាក់សន្សំនៅក្នុងគណនី គ្រឹះស្ថាន អង្គរ មីក្រូហិរញ្ញវត្ថុ(កម្ពុជា)ហៅកាត់ AMK ពិតប្រាកដមែន ប៉ុន្តែភាគីចុងចម្លើយឈ្មោះ [redacted] បញ្ជាក់ថា ខ្លួនបានដកចំណាយអស់ទៅហើយ គប្បីតុលាការមិនលើកយកមកពិចារណាឡើយ ។

៤.តាមការពិនិត្យ លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦,លិខិតបញ្ជាក់ផ្ទេរសិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៦ និងបញ្ជីលេខកូដក្បាលដីភូមិសន្តិភាព ឆ្នាំ២០១៩ លេខ ១៩៩/១៩ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ ព្រមទាំងសេចក្តីថ្លែងការណ៍របស់គូភាគី បានបញ្ជាក់ថា ដីនៅភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលមានលេខក្បាលដី ៥៩១ ក.សរភ ,ដីមានក្បាលដីលេខ ៦៩៦ ក.សរភ មានទីតាំងនៅភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ,ដីនៅភូមិស្នាសង្គ្រាម ឃុំបល្ល័ង្គ ស្រុកបាគង ខេត្តសៀមរាប ដែលមានក្បាលដីលេខ ២៣៦៨ ជាទ្រព្យសម្បត្តិរវាងដើមចោទ និងចុងចម្លើយ ។

៥.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងចុងចម្លើយ បានបញ្ជាក់ថា ដីនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ,ដីនៅភូមិសន្តិភាព ឃុំពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ជាទ្រព្យសម្បត្តិរវាងដើមចោទ និងចុងចម្លើយ ។

៦.តាមការពិនិត្យប័ណ្ណសម្គាល់យានជំនិះ និងសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] រួមទាំងចុងចម្លើយឈ្មោះ [redacted] បានបញ្ជាក់ថាឡានមួយគ្រឿងម៉ាក កាមេរី ០៧ ពណ៌ស ផលិតឆ្នាំ២០០៧ មានផ្លាកលេខ ព្រះសីហនុ 2D-0809 ជាទ្រព្យសម្បត្តិរវាងដើមចោទ និងចុងចម្លើយ ប៉ុន្តែតាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] បានបញ្ជាក់ថា ខ្លួនបានលក់រថយន្តនោះបាត់ទៅហើយ គប្បីតុលាការមិនលើកយកមកពិចារណាឡើយ ។

៧.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទនិងចុងចម្លើយបានបញ្ជាក់ថា ពួកខ្លួនមានម៉ូតូចំនួន ០៣គ្រឿងទី១ ម៉ូតូម៉ាក ហុងដា ភីស៊ីអិច ពណ៌ស ក្រហម ឆ្នាំ២០២០ ,ទី២ ម៉ូតូ យ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និងទី៣ ម៉ូតូ ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅ ប៉ុន្តែចុងចម្លើយបានបញ្ជាក់ថា ខ្លួនបានលក់ម៉ូតូមួយគ្រឿង ម៉ាក ហុងដា ភីស៊ីអិច ពណ៌ស ក្រហម ផលិតឆ្នាំ២០២០ បាត់ទៅហើយ សព្វថ្ងៃនេះនៅមានតែម៉ូតូចំនួន ២គ្រឿងប៉ុណ្ណោះ គឺម៉ូតូ យ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និង ម៉ូតូ ម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅ គប្បីតុលាការលើកយកម៉ូតូដែលមានជាក់ស្តែងចំនួនពីរគ្រឿងមកពិចារណាប៉ុណ្ណោះ ។

៨.តាមសេចក្តីថ្លែងការណ៍របស់ដើមចោទថា ខ្លួននិងចុងចម្លើយមានគ្រឿងអលង្ការ ០១ឈុត សរុបជាប្រាក់ចំនួន ១៩,៥០០ដុល្លារអាមេរិក(មួយម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) រួមមានខ្សែដៃមាសជិត ពីរតម្លឹង ,ជញ្ជៀនពេជ្រពីរវង្ស ,បន្តោងខ្សែកពេជ្រពីរបន្តោង ,ក្រវិលពេជ្រពីរគូ , ខ្សែករផ្កាកទីន ជិតពីរតម្លឹង ខ្សែករមាសចំនួន ២ខ្សែ សរុបពីរតម្លឹង រួមទាំងលុយក្នុងទូរដែកចំនួន ៥,៥០០ដុល្លារ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក) ប៉ុន្តែចុងចម្លើយបានអះអាងថា គ្រឿងអលង្កាចំនួន ០១ឈុត សរុបជាប្រាក់ចំនួន ១៩,៥០០ដុល្លារអាមេរិក(មួយម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) រួមមានខ្សែដៃមាសជិត ពីរតម្លឹង ,ជញ្ជៀនពេជ្រពីរវង្ស ,បន្តោងខ្សែកពេជ្រពីរបន្តោង , ក្រវិលពេជ្រពីរគូ , ខ្សែករផ្កាកទីន ជិតពីរតម្លឹង ខ្សែករមាសចំនួន ២ខ្សែ សរុបមួយតម្លឹង រួមទាំងលុយក្នុងទូរដែកចំនួន ៥,៥០០ដុល្លារ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក) មិនមានដូចសេចក្តីថ្លែងការណ៍របស់ដើមចោទទេ ម្យ៉ាងទៀតដើមចោទពុំមានភស្តុតាងណាមួយមកបញ្ជាក់ ថាពិតជាមានគ្រឿងអលង្ការ ០១ឈុត សរុបជាប្រាក់ចំនួន ១៩,៥០០ដុល្លារអាមេរិក(មួយម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) និងលុយក្នុងទូរដែកចំនួន ៥,៥០០ដុល្លារ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក) ដាក់ជូនតុលាការពិនិត្យឡើយ ដូច្នេះឃើញថា គ្មានភស្តុតាងណាមួយបានបញ្ជាក់ថា មានគ្រឿង

អលង្កា ០១ឈុត សរុបជាប្រាក់ចំនួន ១៩,៥០០ដុល្លារអាមេរិក(មួយម៉ឺនប្រាំបួនពាន់ប្រាំរយដុល្លារអាមេរិក) និងលុយក្នុងទូរដែកចំនួន ៥,៥០០ដុល្លារ (ប្រាំពាន់ប្រាំរយដុល្លារអាមេរិក)នោះទេ គប្បីតុលាការច្រានចោលការទាមទារអំពីគ្រឿងអលង្ការ និងលុយនៅក្នុងទូដែកនេះ ។

៩.ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ដើមចោទ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១.ច្រានចោលពាក្យបណ្ដឹងសុំលែងលះរបស់ដើមចោទឈ្មោះ [redacted] ដែលមិនត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២.ឱ្យដើមចោទឈ្មោះ [redacted] ជាប្ដីមានសិទ្ធិអំណាចមេបាលើកូនចំនួន ០១នាក់ ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៧ ។

៣.ចុងចម្លើយឈ្មោះ [redacted] ជាប្រពន្ធមានសិទ្ធិអំណាចមេបាលើកូនចំនួន ០១នាក់ ឈ្មោះ [redacted] កេត ភេទស្រី កើតឆ្នាំ២០២១ ។

៤.ឱ្យដើមចោទឈ្មោះ [redacted] ជាប្ដីបង់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៥.ចុងចម្លើយឈ្មោះ [redacted] ជាប្រពន្ធបង់អាហារកិច្ចចិញ្ចឹមកូនតាមលទ្ធភាព ។

៦.ឱ្យអ្នកមានសិទ្ធិអំណាចមេបាឈ្មោះ [redacted] និងឈ្មោះ [redacted] ត្រូវផ្ដល់ភាពងាយស្រួលគ្រប់បែបយ៉ាង ដល់ភាគីម្ខាងទៀតដែលត្រូវជាឪពុកម្ដាយ មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងកូន ពេលណាក៏បាន តែត្រូវគិតដល់ផលប្រយោជន៍កូនជាអទិភាព តាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី ។

៧.បែងចែកទ្រព្យរួមដូចខាងក្រោម៖

ក.ប្រគល់ដីដែលមានក្បាលដីលេខ ៧៧៤៧ នៅភូមិផ្សារកណ្ដាល សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រង ។

ខ.ប្រគល់ដីទំហំ ១០,៤៦៤ម៉ែត្រការ៉េ មានក្បាលដីលេខ ១៩៩/១៩ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ នៅភូមិសន្តិភាព ឃុំពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ឱ្យទៅដើមចោទជាអ្នកគ្រប់គ្រង ។

គ.ប្រគល់ដីនៅភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដែលមានក្បាលដីលេខ ៥៩១ ក.សរភ ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង ។

ឃ.ប្រគល់ដីដែលមានក្បាលដីលេខ ៦៩៦ ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង ។

ង.ប្រគល់ដីនៅភូមិស្នាសង្គ្រាម ឃុំបល្ល័ង្គ ស្រុកបាគង ខេត្តសៀមរាប ឱ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង ។

ច.បង្គាប់ឱ្យចុងចម្លើយប្រគល់ឯកសារផ្សេងៗដែលពាក់ព័ន្ធដល់ដើមចោទ ។

ឆ.បង្គាប់ឱ្យដើមចោទប្រគល់ឯកសារផ្សេងៗដែលពាក់ព័ន្ធដល់ចុងចម្លើយ ។

ជ.ម៉ូតូចំនួន ០២គ្រឿងទី១ ម៉ូតូយ៉ាម៉ាហា ស៊ីរូស ពណ៌ខ្មៅ ឆ្នាំ២០២១ និងទី២ ម៉ូតូម៉ាក ហុងដា វេវ ពណ៌ក្រហមខ្មៅ ប្រគល់ឱ្យដើមចោទ និងចុងចម្លើយម្នាក់មួយគ្រឿង ។

30/15

សាលក្រមនេះ បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ ២០២៣ និងប្រកាសនៅសវនាការជាអសាធារណៈ នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣ ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងអំឡុងពេល ១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

| ក្រឡាបញ្ជី | ចៅក្រម |
|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **រុន សុខហេង** | **ឈឹម ឬទ្ធី** |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

បន្ទាយមានជ័យ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២៣

**បានឃើញ**
**ចៅក្រម**

**ឈឹម ឬទ្ធី**

**ក្រឡាបញ្ជី**

**រុន សុខហេង**